ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យ នៅប្រទេសកម្ពុជា

# THE IMPORTANCE OF INVESTING IN REAL ESTATE IN CAMBODIA

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យ នៅប្រទេសកម្ពុជា

THE IMPORTANCE OF INVESTING IN REAL ESTATE IN CAMBODIA


គ្រូណែនាំ៖ សោម រិទ្ធី


ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទៈ សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សោម រិទ្ធី

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយកមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករងមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ ទីផ្សារបច្ចុប្បន្ននៅក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវការអនុវត្តកិច្ចការ គណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីធ្វើឱ្យការសិក្សារបស់និស្សិតឱ្យកាន់តែមានគុណភាពខ្ពស់សាកល វិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សា ក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការ អនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រម ទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុង ន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុម យើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំធ្វើការសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយដែល ស្តីពី (**សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា**)យកមកធ្វើការសិក្សាស្រាវជ្រាវ និងបានចងក្រងនៅក្នុងគោលបំណង ដើម្បីឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យបានយល់កាន់តែស៊ីជម្រៅពីការ រៀបចំនៃសារណា និងប្រសិទ្ធភាពនៃការធ្វើម៉ាឃីតជីង។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះ ឡើងនឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃ ទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអាន ទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹង ទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ពៅ គីមឡៀង
ID: B22/ 976



ហាវ និស្ស័យ
ID: B22/1433



ចាន់ ស៊ីនញ៉ា
ID: B22/1037



ឡេង ស្រីលីន
ID: B22/835



ហេង ម៉ានីកា
ID: B22/984

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកល វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិកា១នៃសាកលវិទ្យាល័យ វ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះគ្រូណែនាំ **សោម រិទ្ធី** ជាគ្រូណែនាំដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យ វ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកល វ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា " នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

T.eang

ពៅ គីមទៀង

# សេចក្ដីសង្ខេបនៃការស្រាវជ្រាវ

ក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ យើងសង្កេតឃើញថាវិស័យអចលនទ្រព្យគឺមានការរីកចម្រើនយ៉ាងខ្លាំងមិនថាក្នុងស្រុក និងនៅក្រៅស្រុកគឺហាក់ដូចជាស្ទុះឡើងយ៉ាងរហ័សពីមួយថ្ងៃទៅមួយថ្ងៃ។ មួយវិញទៀតវិស័យនេះ គឺពិតជាមានការរីកចម្រើនយ៉ាងខ្លាំងទើបធ្វើឱ្យការកើនឡើងនូវសេវាកម្មជាច្រើនដូចជា ការទិញ លក់ បញ្ចាំ អចលនទ្រព្យ និងការវាយតម្លៃទៅលើអចលនទ្រព្យទាំងក្រៅស្រុក និងនៅក្នុងស្រុកព្រមទាំងសេវាកម្មផ្សេងៗទៀតដែលទាក់ទងទៅនឹងផ្នែកអចលនទ្រព្យ។ ដោយសារហេតុនេះហើយទើបក្រុមសារណាយើងខ្ញុំជ្រើសរើសសរសេរនូវប្រធានបទស្ដីពី សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា។

ដើម្បីឱ្យការស្រាវជ្រាវលើការចងក្រងសារណាមួយនេះឱ្យកាន់តែមានភាពស៊ីជម្រៅពី សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា ខាងលើនេះក្រុមយើងខ្ញុំសុំលើកយកនូវ ទ្រឹស្ដីដែលបានសិក្សារួចមក ហើយមកធ្វើការប្រៀបធៀបទៅនឹងការជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាដើម្បីយកមកធ្វើជាវិធីសាស្ត្រនៅក្នុងការស្រាវជ្រាវ។ លើការសិក្សាស្រាវជ្រាវពីសកម្មភាពនៃអចលនទ្រព្យប្រទេសកម្ពុជាគឺពិតជាបានបង្ហាញនូវការយល់ដឹងអំពីវិស័យអចលនទ្រព្យ និងសារៈសំខាន់របស់អចលនទ្រព្យនាពេលបច្ចុប្បន្ននិងអនាគត។

លទ្ធផលជាក់ស្ដែងនៃការស្រាវជ្រាវគឺបានឆ្លុះបញ្ចាំពីភាពខុសគ្នា និងដូចគ្នានៃការសិក្សាទៅលើទ្រឹស្ដីដើម្បីថ្លឹងថ្លែងពីបែបបទ និងធ្វើឱ្យអចលនទ្រព្យនៃប្រទេសកម្ពុជាមានដំណើរការបានល្អ។ បន្ទាប់ពីបានសិក្សាទៅលើដំណើរការប្រតិបត្តិការ នៃអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជារួចមកយើងនឹងធ្វើការសិក្សាស្រាវជ្រាវទៅលើចំណុចសំខាន់ៗមួយចំនួនទៀតដូចជាការទំនាក់ទំនងល្អជាមួយនឹងដៃគូរអាជីវកម្ម និងវិភាគទៅដល់បញ្ហាដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាដែលរួមមាន ចំណុចខ្សោយដែលប្រទេសកម្ពុជាសព្វថ្ងៃប្រព្រឹត្តិទៅទាំងមិនដឹងខ្លួន។ នៅក្នុងការផ្ដល់អនុសាសន៍ខ្លះនៅក្នុងន័យរិះគន់ដើម្បីស្ថាបនា ហើយដើម្បីបង្កើននូវប្រសិទ្ធភាពឱ្យបានខ្ពស់ដល់ប្រទេសកម្ពុជា ក្នុងការត្រិះរិះពិចារណាទៅលើចំណុចណាមួយដែលអាចផ្ដល់ប្រយោជន៍ល្អៗសម្រាប់លើវិស័យអចលនទ្រព្យនេះនាពេលអនាគត។

# មាតិកា

ទំព័រ


អារម្ភកថា ........ i
រចនាសម្ព័នក្រុម ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ២
១.៦.១ចំពោះក្រុមអ្នកស្រាវជ្រាវ ........ ២
១.៦.២ ចំពោះកម្ពុជា ........ ៣
១.៦.៣ ចំពោះសង្គម ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី២
## ការវិនិយោគលើវិស័យអចលនទ្រព្យ


២.១ លក្ខណៈទូទៅនៃការវិនិយោគលើវិស័យអចលនទ្រព្យ ........ ៤
២.១.១ និយមន័យអចលនទ្រព្យ ........ ៤
២.១.២ ប្រវត្តិនៃវិស័យអចលនទ្រព្យ ........ ៤
២.១.៣ ប្រភេទនៃអចលនទ្រព្យសំខាន់ៗ ........ ៥
២.២ កត្តាដែលធ្វើឱ្យការវិនិយោគក្នុងវិស័យអចលនទ្រព្យមានការរីកចម្រើន ........ ៦
២.២.១ និយមន័យការវិនិយោគ ........ ៦
២.២.២ ប្រវត្តិនៃការវិនិយោគ ........ ៦
២.២.៣ ប្រភេទនៃការវិនិយោគ ........ ៧

២.២.៤ ទ្រឹស្តីពាក់ព័ន្ធនិងការវិនិយោគ.......................................................................................៩
២.៣ សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យសម្រាប់សេដ្ឋកិច្ច ...................................១០
២.៣.១ និយមន័យសេដ្ឋកិច្ច ..........................................................................................១០
២.៣.២ ប្រព័ន្ធសេដ្ឋកិច្ច ...............................................................................................១០

## ជំពូកទី៣

## សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា

៣.១ ស្ថានភាពទូទៅរបស់កម្ពុជា.............................................................................................. ១៣
៣.១.១ ប្រវត្តិប្រទេសកម្ពុជា................................................................................................ ១៣
៣.១.២ គោលនយោបាយ និងចក្ខុវិស័យនៅកម្ពុជា ....................................................................... ១៣
៣.២ កត្តានៃការវិនិយោគលើវិស័យអចលនទ្រព្យមានការរីចម្រើន.................................................១៥
៣.២.១ កត្តាសេដ្ឋកិច្ច ...................................................................................................១៥
៣.២.២ កត្តាវិនិយោគដោយផ្ទាល់ពីបរទេស ...........................................................................១៦
៣.២.៣ កត្តាសន្តិភាព និងស្ថិរភាពនយោបាយ ......................................................................១៦
៣.៣ សំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យបាននៅសេដ្ឋកិច្ចកម្ពុជា ..................................១៧
៣.៣.១ វិស័យអចលនទ្រព្យ................................................................................................ ១៧
៣.៣.២ ការវិនិយោគអចលនទ្រព្យ.......................................................................................១៨

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.............................................................................................២០
៤.២ ការវិភាគលើចំណុចខ្សោយ .........................................................................................២០

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ......................................................................................................២២
៥.២ ការផ្តល់អនុសាសន៍ ..................................................................................................... ២២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងតែមានការរីកលូតលាស់យ៉ាងខ្លាំងទៅលើគ្រប់វិស័យទាំងអស់ ដូចជា វិស័យអប់រំ វិស័យសុខាភិបាល វិស័យទេសចរណ៍ ជាពិសេសទៅលើវិស័យអចលនទ្រព្យ។ បច្ចុប្បន្នបើយើងក្រឡេកទៅមើលវិស័យអចលនទ្រព្យនេះវិញយើងឃើញថាមានការរីកចម្រើនយ៉ាងខ្លាំងព្រោះវិស័យនេះបានជួយស្តារសេដ្ឋកិច្ចឱ្យកាន់តែមានការរីកចម្រើន និងការអភិវឌ្ឍដ៏មានប្រសិទ្ធភាពដែលជាហេតុនាំឱ្យអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកដែលធ្វើឱ្យមានចំណាប់អារម្មណ៍បានមកធ្វើការវិនិយោគជាច្រើនដង ហើយធ្វើឱ្យការវិនិយោគមួយនេះមានការកើនឡើងបានយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា។

វិស័យអចលនទ្រព្យបានជួយទៅដល់សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ដែលបានផ្តល់ឱកាសទៅដល់អ្នកវិនិយោគិនទាំងក្នុងប្រទេស និងក្រៅប្រទេសសហការគ្នាដើម្បីអភិវឌ្ឍន៍វិស័យសំណង់ និងដីធ្លីដែលធ្វើឱ្យមានអគារពាណិជ្ជកម្មធំៗ និងផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋ ដែលអាចឱ្យពួកគេរកប្រាក់ចំណូលបានច្រើនពីវិស័យនេះដូចជាការទិញ លក់ បង់រំលស់ និងបញ្ចាំអចលនទ្រព្យជាដើម។ ម្យ៉ាងវិញទៀត បើយើងក្រឡេកទៅមើលស្ថានភាពសង្គមវិញ វិស័យអចលនទ្រព្យ គឺបានជួយដល់ប្រជាពលរដ្ឋយើងឱ្យមានការងារធ្វើ ដែលជាការរួមចំណែកមួយក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ពីព្រោះវាបានបង្កើតនូវឱកាសការងារដល់អ្នកដែលគ្មានការងារធ្វើ។ លើសពីនេះទៀតវិស័យនេះ មិនត្រឹមតែជួយឱ្យប្រជាជនមានការងារ ធ្វើនោះទេថែមទាំងជួយឱ្យមានការរីកចម្រើនទៅដល់ប្រទេសជាតិតាមរយៈការប្រមូលពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗទៀតទៅតាមប្រភេទនៃអចលនទ្រព្យ។

ដោយមើលឃើញថាពីផលប្រយោជន៍ក៏ដូចជា ការរីកចម្រើននៃវិស័យអចលនទ្រព្យក្រុមយើងខ្ញុំបានលើកយកប្រធានបទ (**សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា**) មកធ្វើការស្រាវជ្រាវ និងរៀបចំជាសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់វិស័យអចលនទ្រព្យសព្វថ្ងៃនេះ យើងសង្កេតឃើញថាមានការរីកចម្រើនយ៉ាងខ្លាំង មិនថាក្នុងស្រុកឬក្រៅស្រុក ហើយវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការទ្រទ្រង់ និងផ្តល់កំណើនដល់សេដ្ឋកិច្ចនៅប្រទេសកម្ពុជាឱ្យមានការរីកចម្រើនលើគ្រប់វិស័យ។ ទោះបីជាវិស័យនេះមានការីកចម្រើនក៏ដោយប៉ុន្តែអ្នកវិនិយោគ ឬអ្នកដែលមានបំណងចង់ទិញអចលនទ្រព្យ គួរតែសិក្សាស្វែងយល់ព័ត៌មានខ្លះៗដែលធ្វើឱ្យយើងមានទំនុកចិត្តក្នុងការវិនិយោគរួមមាន ពិនិត្យឯកសារ ពេលវេលានៃការអភិវឌ្ឍ ការស្គាល់ទីតាំងភូមិសាស្ត្រ យល់ដឹងពី ព័ត៌មាន ប្រភេទអចលនទ្រព្យ...។ ដូច្នេះហើយទើបក្រុមយើងខ្ញុំចោទជាសំណួរដូចតទៅៈ

១. តើកត្តាអ្វីខ្លះដែលធ្វើឱ្យការវិនិយោគលើវិស័យអចលនទ្រព្យមានការរីចម្រើន ?

២. តើការវិនិយោគលើវិស័យអចលនទ្រព្យបានផ្តល់សារៈសំខាន់អ្វីខ្លះដល់សេដ្ឋកិច្ចកម្ពុជា ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីវិស័យអចលនទ្រព្យ ( ទិញ លក់ )

- ដើម្បីស្វែងយល់ពីកត្តានៃការវិនិយោគលើវិស័យអចលនទ្រព្យមានការរីកចម្រើន
- ដើម្បីស្វែងយល់ពីសារៈសំខាន់នៃការវិនិយោគអចលទ្រព្យនៅក្នុងសេដ្ឋកិច្ចកម្ពុជា

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ដោយសារពេលវេលាមានកំណត់ទំហំនៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតតែទៅលើដំណើរការនៃការវិនិយោគ និងសារៈសំខាន់របស់អចលនទ្រព្យនាសម័យបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ឆ្លងតាមការសិក្សាស្រាវជ្រាវទៅលើវិស័យអចលនទ្រព្យនៅកម្ពុជា វាបានឆ្លុះបញ្ចាំងឱ្យឃើញថាវិស័យមួយនេះកំពុងមានការរីកលូតលាស់យ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ ចំណែកឯវិស័យអចលនទ្រព្យនៅក្នុងអំឡុងពេល១ឆ្នាំមកនេះមានការអភិវឌ្ឍឈានឡើងជាលំដាប់ ហេតុនេះហើយទើបយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវទៅលើរបាយការណ៍នៅក្នុងឆ្នាំ២០២២។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ មួយនេះបានប្រើប្រាស់នៅក្នុងវិធីសាស្ត្រតាមបែបគុណវិស័យសម្រាប់រៀបរាប់ពីផលប្រយោជន៍ នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជាសម្រាប់ធ្វើការសម្រេចចិត្តក្នុងការប្រមូលទិន្នន័យធ្វើឡើងដោយផ្អែកទោលើគេហទំព័រចំនួនបី។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ដោយធ្វើឡើងតាមរយៈគេហទំព័រចំនួនមួយ harbor-propertyដើម្បីយកមកដោះស្រាយទៅលើកត្តាដែលធ្វើឱ្យការវិនិយោគលើវិស័យអចលនទ្រព្យមានការរីចម្រើន ដើម្បីសំយោគឯកសារដែលបានមកពីគេហទំព័រមួយនេះនៅក្នុងគោលបំណងបញ្ជាក់ពីកត្តាដែលធ្វើឱ្យការវិនិយោគលើវិស័យអចលនទ្រព្យមានការរីកចម្រើន។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យដោយធ្វើឡើងតាមរយៈគេហទំព័រចំនួនពីរ៖ khsearch( វប្បធម៌ទូទៅ ) និង MekongView Condo ដើម្បីសំយោគឯកសារដែលបានមកពីគេហទំព័រមួយនេះ ក្នុងគោលបំណងបញ្ជាក់ពីការវិនិយោគលើវិស័យអចលនទ្រព្យបានផ្តល់សារៈសំខាន់ដល់សេដ្ឋកិច្ចកម្ពុជា។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ពិតជាផ្តល់សារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន ជាពិសេសចំពោះ៖

### ១.៦.១ ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់

- ជួយបង្កើនចំណេះដឹង ជំនាញ សមត្ថភាពផ្ទាល់ខ្លួន ដោយការអនុវត្តជាក់ស្តែង
- យល់ដឹងឱ្យកាន់តែច្បាស់ពី ការវិនិយោគលើវិស័យអចលនទ្រព្យ

- យល់ដឹងពី កត្តានៃការវិនិយោគលើវិស័យអចលនទ្រព្យមានការរីចម្រើន
- ចេះធ្វើការងារជាក្រុម និងចេះសម្របសម្រួលជាក្រុម
- ពង្រឹងបន្ថែមលើទំនួលខុសត្រូវលើការស្រាវជ្រាវ

### ១.៦.២ ចំពោះកម្ពុជា

- ផ្សព្វផ្សាយពីការវិនិយោគលើវិស័យអចលនទ្រព្យ
- បានយល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយដើម្បីយកមកអភិវឌ្ឍន៍ឱ្យមានការរីកចម្រើន

### ១.៦.៣ ចំពោះសង្គម

- បានផ្សព្វផ្សាយពីចំណេះដឹងទៅដល់និស្សិតជំនាន់ក្រោយ
- ចងក្រងជាឯកសាសម្រាប់សិស្សប្អូនជំនាន់ក្រោយ

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទ "សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យកម្ពុជា"ដើម្បីជាការបកស្រាយ និងទៅលើប្រធានបទខាងលើឱ្យកាន់តែច្រើនទៀតនោះក្រុមយើងខ្ញុំសូមនាំយកនូវរចនាសម្ព័ន្ធនៃការស្រាវជ្រាវមានបង្ហាញ៖

➢**ជំពូកទី១ ៖ សេចក្តីផ្តើម៖** និយាយសង្ខេបពីលំនាំបញ្ហា គោលបំណងនៃការស្រាវជ្រាវ ចំណោទបញ្ហា ដែនកំណត់ និងវិសាលភាពហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សា ស្រាវជ្រាវ ។

➢**ជំពូកទី២ ៖ ការវិនិយោគលើវិស័យអចលនទ្រព្យ៖** បង្ហាញពីលក្ខណៈទូទៅនៃការវិនិយោគលើវិស័យអចលនទ្រព្យ និយមន័យការវិនិយោគ ប្រភេទនៃការវិនិយោគ ប្រវត្តិទូទៅដែលពាក់ព័ន្ធនឹង ទ្រឹស្តី របស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ។

➢**ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវ៖** បង្ហាញពីស្ថានភាពទូទៅនៃវិស័យអចលទ្រព្យ ប្រវត្តិប្រទេសកម្ពុជា គោលនយោបាយ និងចក្ខុវិស័យនៅកម្ពុជា កត្តានៃការវិនិយោគលើវិស័យអចលនទ្រព្យមានការរីចម្រើន សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យបាននៅកម្ពុជា។

➢**ជំពូកទី៤ ៖ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ៖** ការវិភាគ និងធ្វើការស្វែងយល់លើ ចំណុចខ្លាំង និង ចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

➢**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍សន្និដ្ឋាន ៖** ទៅលើចំណុចទាំងអស់ដែល នៅក្នុង អត្ថបទ និងផ្តល់អនុសាសន៍ទៅលើទៅចំណុចដែលមានកង្វះខាតដើម្បីការកែលម្អ។

# ជំពូកទី២
# ការវិនិយោគលើវិស័យអចលនទ្រព្យ

## ២.១ លក្ខណៈទូទៅនៃការវិនិយោគលើវិស័យអចលនទ្រព្យ

បច្ចុប្បន្នការវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា បានផ្តល់អាទិភាពខ្ពស់ទាំងនៅក្នុងស្រុក និង ក្រៅស្រុក និងអន្តរជាតិក្នុងការសម្រេចចិត្តដាក់ទុនវិនិយោគបន្ថែមមិនស្ទាក់ស្ទើរឡើយស្របពេលដែលកម្ពុជាមានការអភិវឌ្ឍទៅមុខពីមួយថ្ងៃទៅមួយថ្ងៃ។

តាមស្ថានភាពជាក់ស្តែងបើយើងយកចិត្តទុកដាក់ ពីវឌ្ឍនភាពហេដ្ឋារចនាសម្ព័ន្ធផ្សេងៗហាក់ដូចជាមានភាពល្អដដែរ។ តែប្រសិនបើម្ចាស់អចលនទ្រព្យមិនមានចក្ខុវិស័យទូលំទូលាយជាមួយនឹងតួនាទីសំខាន់លើវិស័យអចលនទ្រព្យនោះទេប្រាកដណាស់វានឹងបរាជ័យជាក់ជាមិនខាន។

ដើម្បីទទួលបានសមិទ្ធិផលនៅក្នុងការវិនិយោគផ្នែកអចលនទ្រព្យ អ្នកជំនួញត្រូវមានគោលការណ៍ផ្ទាល់ខ្លួន ស្វែងរកតំបន់ណាដែលមានសក្តានុពលខ្ពស់ហើយស្របទៅនឹងទីផ្សារអចលនទ្រព្យ។

### ២.១.១ និយមន័យអចលនទ្រព្យ

ពាក្យថា អចលនទ្រព្យនៅក្នុងផ្លូវច្បាប់ គឺជាដី ឬទ្រព្យសម្បត្តិផ្សេងទៀតដែលនៅជាប់ជាមួយដី ដែលមានលក្ខណៈស្ថិតស្ថេរ មាំមួន ដូចជាអគារ លំនៅឋាន ខុនដូ អាគារពាណិជ្ជកម្ម បន្ទប់ស្នាក់នៅ និងសិទ្ធទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធដីធ្លី រួមមានទាំងប្លង់ដី ហើយវាក៏មានការរួមបញ្ចូលទាំងសិទ្ធនៅក្នុងលំហអាកាស ខាងលើ និងខាងក្រោមដីរៀងៗខ្លួន[1]។

ពាក្យអចលនទ្រព្យ សំដៅដល់ដី ផ្ទះ អាគារ និងសំណង់ផ្សេងៗ ទោះបីបានចុះបញ្ជី ឬមិនចុះបញ្ជីដោយរដ្ឋបាលសុរិយោដី [2]។

អចលនទ្រព្យត្រូវបានកំណត់ថាជាដី និងសំណង់អចិន្ត្រៃយ៍ ដូចជាផ្ទះ ឬការកែលម្អដែលភ្ជាប់ទៅនឹងដី មិនថាធម្មជាតិ ឬបង្កើតឡើងដោយមនុស្ស[3]។

អចលនទ្រព្យ ជាលក្ខណៈនៃគំរូ ដែលត្រូវបានជួសជុលដោយរដ្ឋរបស់វា[4]។

នៅក្នុងគីមីសាស្ត្រអចលនទ្រព្យ គឺជាទ្រព្យសម្បត្តិរបស់សារធាតុមួយ ដែលមានឯករាជ្យនៃបរិមាណសារធាតុ[5]។

### ២.១.២ ប្រវត្តិនៃវិស័យអចលនទ្រព្យ

នៅថ្ងៃទី ១៥ ខែមករា ឆ្នាំ១៨៦១ លោកវេជ្ជបណ្ឌិត និងលោក Lewis Cass រួមជាមួយនឹងបុរស ចំនួន ៦នាក់មកពីតំបន់Martinez ដែលបានមូលមតិគ្នាបង្កើតក្រុមហ៊ុន រ៉ែ ធ្យូង ថ្ម(Black Diamond)ស្ថិតនៅSan

[1] PHKASLA PARTNER. Chamroeun. (2022. March 24). *អចលទ្រព្យជាអ្វី?* Retrieved March, 10 2025, from https://phkaslapartner.com/business-kamsan/what-is-properties/

[2] KHsearch. ពន្ធ. (2020, January 23). *តើពាក្យអចលនទ្រព្យសំដៅលើអ្វី?* Retrieved March, 10 2025, from https://www.khsearch.com/qna/28626

[3] Investopedia. JAMESCHEN. (2020, May 31). *What Is Real Estate?* Retrieved March, 10 2025, from https://www.investopedia.com/terms/r/realestate.asp

[4] សឹក ចិន្តា, ស៊ន់ សារាយ, សុន ស្រីនាថ, មាស លីនដា, ជុំ សុភារី. (ឆ្នាំ២០២៣). *សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាន់ទី២០. នៃវិទ្យស្ថាន វ៉ាន់ដា. សន្លឹកទី៤ ទំព័រទី៣២

[5] ដដែល៖

Francisco នៃទីក្រុង California សហរដ្ឋអាមេរិក។ ដើម្បីដឹកយកធ្យូងថ្មនៅតាមតំបន់ ទំនាបភ្នំ ហើយតំបន់នោះស្ថិតនៅឆ្ងាយពី Francisco ប្រមាណជាង៣៥ម៉ាយនៃភូមិភាគឦសានដែលនៅតំបន់នោះមានឈ្មោះថា Mendaberlon ហើយរ៉ែធ្យូងថ្មទាំងនោះត្រូវបានដឹកជញ្ជូនទៅកាន់វ៉ាស៊ីនតោន ចក្រភពអង់គ្លេស កាណាដា និងអូស្ត្រាលីនៅក្នុងចំនួនជាច្រើនតោន។

ហើយវិស័យនេះបានរីកដុះដាលយ៉ាងខ្លាំងនៅប៉ែកអឺរ៉ុប ក្នុងឆ្នាំ១៨៦៥ លោក Alvinza Hayward និងលោក Louis Mouis Mclane ដែលជាអគ្គនាយករបស់ក្រុមហ៊ុន Wells Fargo Express ជាកូនបង្កើតរបស់ រដ្ឋាភិបាលអាមេរិក និងក្រុមអ្នកមូលធនដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ បានទិញភាគហ៊ុនពី ក្រុមហ៊ុន Black Diamond ប្រមាណជាង ៨៥%។ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៨៦៦ មានកិច្ចប្រជុំមួយក្នុង គោលបំណងផ្លាស់ប្តូរឈ្មោះក្រុមហ៊ុន Black Diamond ទៅជាក្រុមហ៊ុនថ្មីមួយឈ្មោះថា Black Diamond Landing ហើយបន្ទាប់មកបង្កើតបានក្រុមរុករករ៉ែធ្យូងថ្មនៅក្រោមទន្លេJoaquinនៃSan francisco សហរដ្ឋអាមេរិក។

ជាអកុសលនៅក្នុងការរុករករ៉ែធ្យូងថ្មនោះបានបណ្តាលឱ្យការផ្ទុះអគ្គីភ័យខ្លាតធំមួយ និងបណ្តាលឱ្យមានមនុស្សស្លាប់ចំនួន ៧នាក់ និងរបួសចំនួន ៨នាក់ ហើយបានបំផ្លាញអគារចំនួន ១៤ ខ្នងក្រោមទន្លេនោះផង។ នៅក្នុងដើមឆ្នាំ ១៨៨៥ មានក្រុមហ៊ុនសម្ព័ន្ធមួយទៀតបានកើតឡើងដែលមានឈ្មោះថាSouthport Land Commercial ដែលបានបង្កើតឡើងដោយម្ចាស់អតីតក្រុមហ៊ុន Black Diamond ដែលធ្វើជាប្រតិបត្តិការ ទៅលើការទិញដីធ្លី និងរុករករ៉ែធ្យូងថ្មហើយក្នុងឆ្នាំ ១៩១២ ក្រុមហ៊ុននេះបានធ្វើការលក់ឡាន ទិញឡាន រហូតដល់ឆ្នាំ ១៩៣០-១៩៤៩ ក្រុមហ៊ុនមួយនេះបានក្លាយខ្លួនទៅជាក្រុមហ៊ុន លក់ដី ទិញដី ទិញផ្ទះ ជួលអគារ ជួលលំនៅដ្ឋានផ្ទះល្វែងនៅក្នុងទីក្រុង Pittsburg ក្នុងឆ្នាំ ១៩៥៣ រហូតដល់បច្ចុប្បន្ន[6]។

**២.១.៣ ប្រភេទនៃអចលនទ្រព្យសំខាន់ៗ**

អ្នកជំនាញក្នុងវិស័យអចលនទ្រព្យបានលើកឡើងថា អចលនទ្រព្យសំខាន់ៗត្រូវបានបែងចែកជា៤ប្រភេទ ដែលកំពុងពេញនិយមនៅប្រទេសកម្ពុជា អចលនទ្រព្យទាំងនោះរួមមាន៖

១ អចលនទ្រព្យជាដី៖ ដីជាប្រភេទអចលនទ្រព្យប្រើប្រាស់ដីក្នុងការសាងសង់ផ្ទះឬអគារពាណិជ្ជកម្មផ្សេងៗដីក៏ត្រូវបានប្រើប្រាស់នៅក្នុងគោលបំណង និងសម្រាប់កសិកម្មដូចជាការប្រើប្រាស់ទៅលើដីសម្រាប់ការដាំដំណាំ និងចិញ្ចឹមសត្វជាដើម។

២ អចលនទ្រព្យពាណិជ្ជកម្ម (commercial real estate)៖ អចលនទ្រព្យប្រភេទនេះមានដូចជា ផ្សារទំនើប,ហាងលក់រាយ, អគារការិយាល័យ, សណ្ឋាគារនិងកាស៊ីណូ, មន្ទីរពេទ្យឯកជន និងគ្រឹះស្ថានអប់រំ។ ប្រភេទនៃអចលនទ្រព្យពាណិជ្ជកម្មនេះមានមុខងារច្រើនជាងអចលនទ្រព្យលំនៅដ្ឋាន។ មិនត្រឹមតែប៉ុណ្ណោះ អចលទ្រព្យពាណិជ្ជកម្មអាចធ្វើឱ្យមានស្ថេរភាពលំហូរសាច់ប្រាក់ច្រើនជាង ព្រោះអគារពាណិជ្ជកម្មនីមួយៗមានបន្ទប់ច្រើនបើធៀបនឹងផ្ទះល្វែង ហើយបន្ថែមពីនេះការដាក់ជួលមានរយៈពេលវែងរហូតដល់៥ទៅ១០ឆ្នាំឯណោះ។

៣ អចលនទ្រព្យឧស្សាហកម្ម៖ ជាប្រភេទអចលនទ្រព្យដែលសំដៅលើរោងចក្រឧស្សាហកម្ម និងឃ្លាំងស្តុកទំនិញជាដើម។

[6] ដដែល៖

៤ អចលនទ្រព្យលំនៅដ្ឋាន (residential real estate)៖ ជាប្រភេទអចលនទ្រព្យដែលប្រើប្រាស់សម្រាប់ការរស់នៅមានដូចជាផ្ទះ ខុនដូ និង អាផាតមិន ជាដើម។ ជាទូទៅ គេអាចវិនិយោគលើអចលនទ្រព្យប្រភេទនេះតាមរយៈការទិញចូលតម្លៃទាប ហើយលក់ចេញយកផលចំណេញ ឬដាក់ជួលបង្កើតដើម្បីបានជាលំហូរសាច់ប្រាក់ទៀងទាត់[7]។

## ២.២ កត្តាដែលធ្វើឱ្យការវិនិយោគក្នុងវិស័យអចលនទ្រព្យមានការរីកចម្រើន

### ២.២.១ និយមន័យការវិនិយោគ

ការវិនិយោគ សំដៅទៅលើការបណ្ដាក់ទុន ជាប្រាក់កាក់ ពេលវេលាឬ ថាមពលក្នុងការធ្វើអ្វីមួយឬច្រើនក្នុងគោលបំណងបានផលត្រឡប់មកវិញក្នុងកំឡុងពេលកំណត់ណាមួយនៅថ្ងៃអនាគត។ ការវិនិយោគអាចប្រើប្រាស់បានទៅលើមនុស្សគ្រប់វ័យ និងគ្រប់ស្ថានភាពទាំងអស់ ឧទាហរណ៍ការវិនិយោគនេះទៅលើក្រុមហ៊ុនការវិនិយោគលើដីធ្លី ផ្ទះឬ ក៏ការវិនិយោគទៅលើចំណេះដឹង ជំនាញជាដើម។ ការវិនិយោគត្រូវការពេលវេលា ប្លង់មេ ការអនុវត្តដោយមនុស្សមួយក្រុម ដែលមានគោលដៅរួម និងដើរតាមប្លង់មេ[8]។

### ២.២.២ ប្រវត្តិនៃការវិនិយោគ

ការវិនិយោគបានចាប់ផ្តើមនៅក្នុងទសវត្សរ៍ឆ្នាំ ១៦០០ នៅពេលដែលស្ថាប័នដូចជា ផ្ទះទទួលយក និងធនាគារពាណិជ្ជករដែលបានយល់ព្រមផ្តល់ហិរញ្ញប្បទាន ទៅដល់ពាណិជ្ជកម្មបរទេសសម្រាប់រដ្ឋាភិបាលរាជាធិបតេយ្យ ឬបុគ្គល និងមូលនិធិបង្គរសម្រាប់គម្រោងវិនិយោគរយៈពេលវែងនៅបរទេស។ នៅអាមេរិកផ្សារហ៊ុនញូវយ៉កបានបើកជាលើកដំបូងនៅក្នុងឆ្នាំ ១៧៩២នៅខណៈដែលប្រទេសដែលរត់គេចខ្លួនបានបោះជំហានយ៉ាងប្រហូកប្រហល់ជាលើកដំបូងរបស់ខ្លួន។ ចំណែកធនាគារវិនិយោគបានក្លាយទៅជាការអនុវត្តទូទៅជាពិសេសនៅក្នុងសហរដ្ឋអាមេរិក នៅចុងសតវត្សទី ១៩ និងដើមសតវត្សទី ២០។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែនៅក្នុងការអនុវត្តនេះមានឫសគល់នៅក្នុងទ្វីបអឺរ៉ុបមជ្ឈិមសម័យ ដោយសារតែឈ្មួញនៅ Siena ប្ល័រិន ហ្សេនណូ និងទីក្រុងអ៊ីតាលីផ្សេងទៀតបានធ្វើការជួញដូរទំនិញដូចជាគ្រាប់ធញ្ញជាតិ គ្រឿងទេស សូត្រ និងលោហធាតុ។ ក្រុមហ៊ុនធនាគារវិនិយោគធំៗ បានរីកដុះដាលនៅក្នុងសហរដ្ឋអាមេរិកដែលចាប់ផ្តើមនៅចុងទសវត្សរ៍ឆ្នាំ១៨០០។ នៅក្រុមហ៊ុន JP Morgan, Goldman Sachs និង Lehman Brothers (ឥឡូវក្ស័យធន)ឈ្មោះធំៗទាំងអស់មានឫសគល់ក្នុងការវិនិយោគនៅក្នុងទសវត្សរ៍ឆ្នាំ១៨០០។ នៅក្នុងទសវត្សរ៍ទី២០ដែលក្រុមហ៊ុនបាននាំមកនូវវិធីសាស្រ្តថ្មីទាំងស្រុង នៅក្នុងការវិនិយោគនៅសហរដ្ឋអាមេរិក។ វិនិយោគិនជាមធ្យមមានកង្វល់ពីចំពោះការវិនិយោគនៅពេលនោះ៖ តើភាគហ៊ុនត្រូវទិញនៅពេលណា និងពេលណាត្រូវលក់វាដើម្បីទទួលបានប្រាក់ចំណេញ។ នេះគឺជាប្រភពដើមនៃគម្រោងទទួលបាននូវអ្នកមានបានយ៉ាងឆាប់រហ័សនៅក្នុងសង្គមអាមេរិក។ អ្នកវិនិយោគិនបានស្វែងរកការវិនិយោគរយៈពេលខ្លីដ៏ល្អ ដែលអាចលក់បានប្រាក់ចំណេញនៅពេលដែលតម្លៃឡើងខ្ពស់។ ទោះបីជាយ៉ាងណាក៏ដោយ វិធីសាស្រ្តប្រថុយប្រថានមួយនេះនៅក្នុងការវិនិយោគនេះនាំឱ្យអ្នកវិនិយោគិនខ្ចីលុយពីឈ្មួញកណ្ដាល ដើម្បីទូទាត់នៃភាគហ៊ុនហើយដូចដែលមនុស្សគ្រប់គ្នាបានដឹងច្បាស់ទីបំផុតបណ្ដាលឱ្យមានការគាំងទីផ្សារភាគហ៊ុននៅឆ្នាំ ១៩២៩។ យុគសម័យថ្មី

---

[7] Property. ម៉ាណេត. (2021, July 30). *តើអចលនទ្រព្យនៅប្រទេសកម្ពុជាមានប៉ុន្មានប្រភេទ?* Retrieved March, 12 2025, from https://propertyarea.asia/archives/78090

[8] ហុក ហេង. (2019, December 12). *និយមន័យការវិនិយោគ.* Retrieved March, 12 2025, from https://www.khsearch.com/qna/27823

នៃការវិនិយោគបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ និងការរីកចម្រើនផ្នែកសេដ្ឋកិច្ចដែលបានកើតឡើង នៅក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៤០ និង ១៩៥០ ទស្សនៈរបស់អាមេរិកលើការវិនិយោគបានចាប់ផ្ដើមផ្លាស់ប្ដូរ។ នៅដើមទសវត្សរ៍នេះ មានតែជនជាតិអាមេរិក ៤.២% ប៉ុណ្ណោះដែលមានភាគហ៊ុនរួម។ នៅឆ្នាំ១៩៥៤ Dow Jones Industrial Average បានឡើងដល់កំពូលនៃឆ្នាំ១៩២៩។ ផលប័ត្រទំនើបបានធ្វើការចាប់ផ្ដើមលេចឡើងដោយសារតែ "ទ្រឹស្ដីផលប័ត្រទំនើប" ដែលបង្កើតឡើងដោយ Harry Markowitz ដែលជាបណ្ឌិត។ និស្សិតនៅសាកលវិទ្យាល័យ Chicago(អ្នកទទួលរង្វាន់ណូបែលផ្នែកសេដ្ឋកិច្ចសម្រាប់ការងារនេះ)។ អ្នកវិនិយោគិនបានចាប់ផ្ដើមបង្កើតផលប័ត្រវិនិយោគដែល ពឹងផ្អែកតិចលើភាគហ៊ុនដែលបានជ្រើសរើសជាលក្ខណៈបុគ្គល និងពេលវេលាទីផ្សារហើយឱ្យផ្ដោតទៅលើការបង្កើនផលត្រឡប់មកវិញ ដោយសារតែការផ្អែកទៅលើចំនួនហានិភ័យដែលពាក់ព័ន្ធទៅលើការបង្កើតផលប័ត្ររួម។ ជាលើកដំបូងអ្នកវិនិយោគបានស្វែងរកនូវការងារធ្វើពិពិធកម្មផលប័ត្រដោយសារតែការវិនិយោគនៅក្នុងថ្នាក់ទ្រព្យសកម្មជាច្រើន។ ក្នុងវិធីសាស្ត្រមួយនេះ នៅតែជាស្តង់ដារនាពេលបច្ចុប្បន្ននេះនៅក្នុងការបង្កើតមូលដ្ឋានគ្រឹះនៃផលប័ត្រណាមួយ។ ការវិនិយោគទំនើបចាប់តាំងពីឆ្នាំ២០១៦វាពិបាកក្នុងការគិតពីទសវត្សរ៍ឆ្នាំ១៩៧០ជា"ទំនើប"។ នៅក្នុងពេលដាក់វានៅក្នុងបរិបទនៃពេលវេលាចាប់ពីតាំងឆ្នាំ១៦០០ដល់ឥឡូវនេះមានច្រើនបានកើតឡើងចាប់តាំងពី ទសវត្សរ៍ឆ្នាំ១៩៧០ដែលវាមិនអាចទៅរួចទេនៅក្នុងការបំបែកវាទាំងអស់នៅក្នុងប្រកាសនេះ។ នៅក្នុងទសវត្សរ៍ទី៧០គឺជាទសវត្សរ៍ដ៏ចម្លែកសម្រាប់ទីផ្សារ ដោយសារតែ DJIA បានកើនឡើងត្រឹមតែ ៥% សម្រាប់ទសវត្សរ៍នេះប៉ុន្តែអ្នកក៏បានឃើញនូវវត្តមានរបស់ NASDAQ(ទីផ្សារភាគហ៊ុនអេឡិចត្រូនិកដំបូង)កំណើននៃមូលនិធិទៅវិញទៅមកការលុបបំបាត់អត្រាកម្រៃជើងសារអេប្បបរមាថេរ និងការណែនាំនៃមូលនិធិសន្ទស្សន៍ដំបូង។ ទសវត្សរ៍ឆ្នាំ១៩៨០បានឃើញអត្រាពន្ធលើការកើនឡើងដើមទុនទាបក្នុងការវិនិយោគ ដែលមាននៅហានិភ័យខ្ពស់ការកើនឡើងនៃការប្រើប្រាស់បំណុលឱ្យមានទិន្នផលខ្ពស់ហើយ NYSE ឈានដល់ទំហំពាណិជ្ជកម្មមួយថ្ងៃ១០០លានជាលើកដំបូងដែលមិនធ្លាប់មាន។ នៅក្នុងឆ្នាំ១៩៩០ច្រើនជាង20%នៃប្រជាជនអាមេរិកឥឡូវនេះមានការកាន់កាប់នៃភាគហ៊ុនទូទៅ(ប្រហែល៥១លាននាក់) ហើយច្បាប់Gramm-Leach-Billey បានដកចេញការបំបែករវាងធនាគារវិនិយោគ និងធនាគារដាក់ប្រាក់។ បន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ចដ៏អស្ចារ្យនាពេលថ្មីៗនេះ ទស្សនៈរបស់អាមេរិកទៅលើការវិនិយោគបានផ្លាស់ប្ដូរ។ មនុស្សបានចាប់ផ្ដើមផ្ដោតលើ និងព្រួយបារម្ភបន្ថែមទៀតអំពីការប្រែប្រួលរយៈពេលខ្លី និងការធ្លាក់ចុះជាជាងការត្រឡប់មកវិញជាវិជ្ជមាន។ នេះជាការពិតនាពេលសម័យបច្ចុប្បន្ននេះដែលមានន័យថា វាជាការល្អបំផុតនៅក្នុងនៃការធ្វើពិពិធកម្មផលប័ត្ររបស់អ្នកដោយប្រើយុទ្ធសាស្ត្រនៃការវិនិយោគជាច្រើនដងដែលពឹងផ្អែកទៅលើការអត់ធ្មត់ហានិភ័យ និងទីផ្សារ។ ការផ្ដោតទៅលើការវិនិយោគរយៈពេលវែងអាចជួយឱ្យបង្រួមអប្បបរមានូវលក្ខណៈពិសេសមួយចំនួន និងឱ្យមានភាពប្រែប្រួលជុំវិញនៃការធ្លាក់ចុះ ប៉ុន្តែនឹងមិនផ្ដល់ដំណោះស្រាយដ៏ល្អឥតខ្ចោះនោះទេ។ សម្រាប់ការជំនួយជាមួយផលប័ត្ររបស់អ្នកនៅក្នុងទីផ្សារចុងក្រោយបំផុតសូមទាក់ទង Indian River Financial Group [9]។

### ២.២.៣ ប្រភេទនៃការវិនិយោគ

[9] Paul Miller. (2016, February 9). *A Brief History of* Investments. Retrieved March, 15 2025, from https://www.paulmilleradvisor.com/blog/brief-history-investments

ប្រភេទនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជា គឺមានច្រើនណាស់ដែលប្រភេទការវិនិយោគនីមួយៗ អាស្រ័យទៅលើដើមទុន ពេលវេលា និងចំណេះដឹងរបស់អ្នកលើការវិនិយោគនោះ។ ការវិនិយោគរមែងមាន ហានិភ័យ និងផលចំណេញឬកំហាត ខុសៗគ្នាអាស្រ័យទៅតាមប្រភេទនៃការវិនិយោគនោះ។

ខាងក្រោមនេះគឺជាប្រភេទនៃការវិយោគមួយចំនួនដែលយើងអាចស្វែងយល់ទាំងអស់គ្នា៖

• ភាគហ៊ុន (Stock)៖ បើអ្នកជាអ្នកវិនិយោគិនថ្មីថ្មោង និងមានទស្សនៈវិស័យលើការវិនិយោគ នោះ ភាគហ៊ុនជាប្រភេទនៃការវិនិយោគដែលអ្នកគួរចាប់ផ្ដើមដំបូង។ សម្រាប់ការវិនិយោគលើភាគហ៊ុនមិនតម្រូវឱ្យ អ្នកចាំបាច់ទាល់តែមានដើមទុនច្រើនបានវិនិយោគបាននោះឡើយ។ រីឯផលចំណេញ(ភាគលាភ)ដែលមាន ប្រតិបត្តិការក្រោមរូបភាពពីរគឺ ការជួញដូរ (trade) ដែលផលចំណេញឬកំហាតនឹងអាចដឹងភ្លាមៗ ចំណែកឯ ការវិនិយោគលើភាគហ៊ុនរយៈពេលវែងនោះវិនិយោគិនអាចរំពឹងបានថា និងទទួលបានផលចំណេញដំកំកួន នៅក្នុងរយៈពេលយូរ។ ហើយការវិនិយោគទៅលើភាគហ៊ុនមានដំណើរការយ៉ាងងាយស្រួលតែវាក៏ទាមទារឱ្យ យើងយល់ដឹងច្រើនពី ទីផ្សារភាគហ៊ុន និងដើម្បីជ្រើសរើសវិនិយោគលើភាគហ៊ុនដែលមានសក្ដានុពលខ្ពស់។

• សញ្ញាប័ណ្ណ(Bond)៖ ជាប្រភេទមូលបត្របំណុល ដែលវិនិយោគិនធ្វើការផ្ដល់កម្ចី ទៅឱ្យក្រុមហ៊ុន សាជីវកម្ម ឬសហគ្រាសសាធារណៈតាមរយៈក្នុងការទិញសញ្ញាប័ណ្ណក្នុងតម្លៃណាមួយ។ អ្នកវិនិយោគិននឹង ទទួលបានប័ណ្ណបញ្ជាក់បំណុល (Debt Security) មួយដែលបញ្ជាក់ពីទឹកប្រាក់ដែលបានវិនិយោគ និងអត្រា ការប្រាក់(ប្រចាំខែ ឬឆ្នាំ) ចំនួនទឹកប្រាក់នឹងត្រូវសងត្រឡប់មកវិញហើយ និងកាលកំណត់នៃសញ្ញាប័ណ្ណ (maturity date)។ ផលចំណេញពី សញ្ញាប័ណ្ណអាស្រ័យទៅលើអត្រាការប្រាក់ដែលសាជីវកម្ម ឬសហគ្រាស នោះសន្យាថា និងសងត្រឡប់មកវិញនៅកាលកំណត់ដូចដែលបញ្ជាក់ក្នុងប័ណ្ណបញ្ជាក់បំណុល។ ហេតុដូច នេះហើយទើបមានហានិភ័យពីការវិនិយោគ នៃសញ្ញាប័ណ្ណត្រូវបានគេសន្មត់ថានៅមានកម្រិតទាបជាងគេបើ ប្រៀបធៀបទៅនឹងប្រភេទនៃការវិនិយោគដទៃទៀត។ បច្ចុប្បន្នបើនៅក្នុងទីផ្សារមូលបត្រកម្ពុជាមិនទាន់មាន សញ្ញាប័ណ្ណសម្រាប់សហគ្រាសសាធារណៈនៅឡើយទេ តែមានសញ្ញាប័ណ្ណរបស់ក្រុមហ៊ុនសាជីវកម្មចំនួន៧ ក្រុមហ៊ុន ដែលបានធ្វើការបោះផ្សាយលក់ឱ្យសាធារណជន។

• ការជួញដូររូបិយប័ណ្ណអន្តរជាតិ (Foreign Exchange ឬ Forex)៖ ការជួយដូររូបិយប័ណ្ណអន្តរជាតិ នេះជាប្រភេទការវិនិយោគរយៈពេលខ្លីត្បិតថាអ្នកវិនិយោគលើវិស័យនេះត្រូវការទិញលក់ភ្លាមៗដោយសារតែ ការជួញដូររូបិយប័ណ្ណអន្តរជាតិទៅវិញទៅមកនៅក្នុងតម្លៃហាងឆេងតាមជាក់ស្ដែងឬ នៅក្នុងតម្លៃដែលបាន កំណត់ណាមួយ។ តែការវិនិយោគប្រភេទនេះត្រូវបានប្រព្រឹត្តឡើងដោយសារការទិញលក់រវាងរូបិយប័ណ្ណពីរ ផ្សេងគ្នា ដូចជាការទិញលក់លុយដុល្លារអាមេរិកធៀបជាមួយលុយអឺរ៉ូជាដើម។ រីឯអ្នកវិនិយោគិន នឹងទទួល បានផលចំណេញកំហាតទៅតាមគម្លាតតម្លៃនៃរូបិយប័ណ្ណ (forex deviation) ឡើងចុះនៅក្នុងរយៈពេលណា មួយ។ ទន្ទឹម នឹងនេះ Forex ក៏ត្រូវបានគេកំណត់ថា ជាការជួញដូរដែលមានហានិភ័យខ្ពស់ បើប្រៀបធៀបទៅ នឹងប្រភេទផ្សេងទៀតដូចជា ភាគហ៊ុន សញ្ញាប័ណ្ណ អចលនទ្រព្យ មាស ។ល។

• អចលនទ្រព្យ (Real Estate)៖ ការវិនិយោគលើអចលនទ្រព្យជាការវិនិយោគរយៈពេលវែង ដោយវា មិនងាយបម្លែងជាសាច់ប្រាក់បានលឿននោះទេ។ អ្នកវិនិយោគតម្រូវឱ្យមានដើមទុនច្រើន តែយ៉ាងណាមិញ ការវិនិយោគប្រភេទនេះ មានសក្ដានុពលអាចផ្ដល់ផលចំណេញវិញបានខ្ពស់ ប្រសិនបើយើងវិនិយោគដោយ

មានយុទ្ធសាស្ត្រ ការវិភាគ កំណើនតម្លៃនៃអចលនទ្រព្យបានច្បាស់លាស់។ ការវិនិយោគលើអចលនទ្រព្យមានដូចជា ការទិញដី ផ្ទះ វីឡា អាផាតមិន (Apartment) ខុនដូ ជាដើម ហើយលក់ចេញវិញយកផលចំណេញនៅពេលតម្លៃកើនឡើង។ ក្រៅពីការលក់វិនិយោគិនក៏អាចជួលបន្តដើម្បីទទួលបានចំណូលជាប្រចាំ ឬ អាចប្រកបរបរផ្សេងៗនៅលើទីតាំងអចលនទ្រព្យបានផងដែរ។

• អាជីវកម្ម (Business) ៖ ការបណ្តាក់ទុនទៅលើគម្រោងការ ក្រុមហ៊ុនឬ អាជីវកម្មណាមួយដែលយើងគិតថាអាចមានការរីកចម្រើននៅពេលខាងមុខ ហើយយើងនឹងត្រូវទទួលបាននូវផលត្រឡប់មកវិញនៅពេលដែលអាជីវកម្មនោះទទួលបានប្រាក់ចំណេញដែលយើងហៅថាprofit share។ ម្យ៉ាងវិញទៀត បើការនេះអ្នកវិនិយោគិនជាម្ចាស់អាជីវកម្មផ្ទាល់ខ្លួនអាចលក់ទៅជាសេវាកម្មឬ ផលិតផលដើម្បីយកផលចំណេញក៏ចាត់ទុកជាការវិនិយោគដែរ។

• បញ្ញើមានកាលកំណត់ (Term Deposit)៖ វាមានភាពស្រដៀងគ្នាជាមួយទៅនិងគណនីសន្សំ (Saving Account) គ្រាន់តែបញ្ញើមានកាលកំណត់តម្រូវឱ្យអ្នកយកចំនួនទឹកប្រាក់ទាំងដុលយកទៅផ្ញើរនៅធនាគារ ជាមួយកាលកំណត់ណាមួយរួម ជាមួយកិច្ចព្រមព្រៀងពីខាងធនាគារផ្តល់អត្រាការប្រាក់ជូនដល់ទៅឱ្យអ្នក។ សម្រាប់ផលចំណេញពីបញ្ញើរមានកាលកំណត់ វាអាស្រ័យលើទំហំទឹកប្រាក់ដែលយកទៅផ្ញើរ និងចំនួនមួយរយៈពេលដែលចង់ដាក់ប្រាក់ផងដែរ។

• ផលិតផលឬវត្ថុធាតុដើម (Commodities)៖ ការវិនិយោគប្រភេទនេះ វាអាស្រ័យទៅលើហាងឆេងនៃតម្លៃរបស់វត្ថុធាតុដើមនិងផលិតផល និងតម្រូវការទីផ្សារក្នុងនិងក្រៅប្រទេស។ ផលិតផលឬ វត្ថុធាតុដើមមានមួយចំនួនដូចជា ប្រេង មាស ប្រាក់ និងវត្ថុធាតុដើមផ្សេងៗទៀត។ អ្នកវិនិយោគលើវិស័យនេះត្រូវសិក្សាស្វែងយល់ពីតម្រូវការ និងការផ្គត់ផ្គង់នៃវត្ថុធាតុដើមទាំងនេះ រួមកត្តាប៉ះពាល់ដល់តម្លៃរបស់វា ដែលអាចមានដូចជា កត្តាសេដ្ឋកិច្ច អតិផរណា និងតម្រូវការជាដើម។

យើងឃើញថា ការវិនិយោគមានច្រើនរបៀបដែលមានដំណើរការ និងផលប្រយោជន៍ត្រឡប់មកវិញផ្សេងៗគ្នាទៅតាមប្រភេទនីមួយៗរៀងខ្លួនដូចគ្នាដែរ ហើយយើងគួរតែជ្រើសរើសប្រភេទនៃការវិនិយោគណាមួយផ្ទាល់ខ្លួនដែលសក្តិសមទៅនឹងដើមទុន ចំណេះដឹង និងចំណង់ចំណូលចិត្តដើម្បីមានការទាញយកផលចំណេញពីវា[10]។

### ២.២.៤ ទ្រឹស្តីពាក់ព័ន្ធនិងការវិនិយោគ

ប្រទេសកម្ពុជា បានរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ បន្ទាប់ពីមានការឆ្លងកាត់នៃសង្គ្រាមអូសបន្លាយ និងអស្ថិរភាពជាច្រើនឆ្នាំ។ សេដ្ឋកិច្ចកម្ពុជាបានកើនឡើងយ៉ាងខ្លាំងក្លាបន្ទាប់ពីមានការផ្លាស់ប្តូររបស់ប្រទេសទៅជាសេដ្ឋកិច្ចទីផ្សារសេរី ដែលនៅក្នុងនោះកម្ពុជាបានបើកចំហឱ្យមានពាណិជ្ជកម្មនិងលំហូរមូលធន។ កំណើនសេដ្ឋកិច្ចនេះ ត្រូវបានគាំទ្រដោយសារតែលំហូរនៃជំនួយការអភិវឌ្ឍន៍ផ្លូវការឱ្យបានចូលទៅកាន់ទីផ្សាររបស់សហគមន៍អ៊ឺរ៉ុប និងសហរដ្ឋអាមេរិកក៏ដូចជា លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

[10] កាក់សេន-Kakcent. (2021, January 22). *ប្រភេទនៃការវិនិយោគ*. Retrieved March, 15 2025, from https://www.facebook.com/kakcentkh/posts/

នៅត្រីមាសទី៣ ឆ្នាំ២០២០ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)បានអនុម័តទៅលើគម្រោងវិនិយោគថ្មីចំនួន២១ គម្រោងដែលបានថយចុះចំនួន២៨គម្រោងវិនិយោគ។ ទោះបីជាយ៉ាងណាក្តី ទុននៃវិនិយោគមានទំហំ៣,៦៣ន់លានដុល្លារអាមេរិក ឬកើនឡើង២២០.៧% បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុនដែលនៅក្នុងនោះភាគច្រើនដើមទុនវិនិយោគមាន ការកើនឡើងខ្លាំងទៅលើការសាងសង់សណ្ឋាគារ ផ្ទះល្វែង មជ្ឈមណ្ឌលពាណិជ្ជកម្ម និងកសិដ្ឋានចិញ្ចឹមសត្វធំៗ។ នៅក្នុងចំណោមនៃការគម្រោងវិនិយោគដែលត្រូវបានអនុម័តក្នុងកំឡុងឆ្នាំ១៩៩៤-២០១៩ ប្រទេសចិនបានធ្វើការកាន់កាប់នូវចំណែកដ៏ធំជាងគេដែលមានចំនួនប្រមាណជា២១.៨%។ គម្រោងដែលបានធ្វើការវិនិយោគទាំងនោះត្រូវបានផ្សាភ្ជាប់ជាមួយទៅនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ផលិតផល កសិឧស្សាហកម្មដូចជា កៅស៊ូក៏ដូចជាទៅលើវិស័យទេសចរណ៍ផងដែរ។ នៅក្នុងចន្លោះឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៨ ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថា ជាប្រទេសមួយដែលមានសេដ្ឋកិច្ច រីកចម្រើនយ៉ាងឆាប់រហ័សនៅលើពិភពលោក ក៏ដោយសារអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមរបស់ខ្លួនក្នុងរង្វង់ ៧.៧%។

កំណើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេសសរុប(FDI) ដែលមានកម្រិតទ្វេដងនៅក្នុងទសវត្សចុងក្រោយជាក់ស្តែង ចំណែករបស់វិនិយោគផ្ទាល់ពីបរទេសគិតជាភាគរយនៃផលិតផលក្នុងស្រុកសរុបកើនឡើងពី ៧.៨% ក្នុងឆ្នាំ ២០០៨ ដល់ ១៣.១%ក្នុងឆ្នាំ ២០១៨ ដែលមានកម្រិតខ្ពស់ជាងប្រទេសដទៃទៀត នៅក្នុងតំបន់យ៉ាងខ្លាំងនេះបើប្រៀបធៀបទៅនឹងប្រទេសថៃ( ១.១%) និងប្រទេសវៀតណាម( ៦.១%) ជាដើម [11]។

## ២.៣ សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យសម្រាប់សេដ្ឋកិច្ច

### ២.៣.១ និយមន័យសេដ្ឋកិច្ច

សេដ្ឋកិច្ច គឺជាសំណុំនៃទំនាក់ទំនង ផលិតកម្ម ការប្រើប្រាស់ ការដោះដូរ និងការបែងចែងធនធានកម្រទាំងឡាយនៅក្នុងសង្គម។ សេដ្ឋកិច្ច មានពីរប្រភេទធំៗគឺ មីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច។ ប្រព័ន្ធសេដ្ឋកិច្ចចែកចេញជាបីគឺ សេដ្ឋកិច្ចផែនការ សេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចចម្រុះ[12]។

សេដ្ឋកិច្ច ជាការសិក្សាពីរបៀបដែលបុគ្គលគ្រួសារសង្គមចេះលៃលកប្រើប្រាស់នូវធនធានដែលមានក្នុងការផលិត ( ទំនិញនិងសេវាកម្ម) ដើម្បីបម្រើសេចក្តីត្រូវការគ្មានដែនកំណត់របស់មនុស្ស [13]។

### ២.៣.២ ប្រព័ន្ធសេដ្ឋកិច្ច

ប្រព័ន្ធសេដ្ឋកិច្ច (Economic systems) ប្រព័ន្ធសេដ្ឋកិច្ចពិភពលោកចែកចេញជា 4 :

-ប្រព័ន្ធសេដ្ឋកិច្ចបុរាណ (Traditional economic system)

-សេដ្ឋកិច្ចបុរាណ ជាប្រព័ន្ធសេដ្ឋកិច្ចដែលពឹងផ្អែកលើមូលដ្ឋានប្រពៃណី ទំនៀមទំលាប់ សហគមន៍ គ្រួសារ ឬ សាសនា។

-ប្រព័ន្ធសេដ្ឋកិច្ចបុរាណមានភាពពេញនិយមជាសេដ្ឋកិច្ចដើមឬ មិនអភិវឌ្ឍន៍នោះឡើយ ដែលមានឧបករណ៍និងបច្ចេកទេសហួសសម័យ ។

---

[11] អង្គភាពទិន្នន័យអំពីការអភិវឌ្ឍ. (2021, February 12). *ការវិនិយោគ.* Retrieved March, 20 2025, from https://opendevelopmentcambodia.net/km/topics/investment/

[12] KHsearch. Chanheng Menh. (2021, April 5). *និយមន័យសេដ្ឋកិច្ច.* Retrieved March, 20 2025, from https://www.khsearch.com/profile/Chanheng_Menh

[13] Wikipedia. (2024, January 10). *សេដ្ឋកិច្ច.* Retrieved March, 7 2025, from https://km.wikipedia.org/wiki/សេដ្ឋកិច្ច

-ប្រព័ន្ធសេដ្ឋកិច្ចបុរាណ គឺពាក់ព័ន្ធ និងការពង្រីកការផលិតក្នុងវិស័យ កសិកម្មដើម្បីផ្គត់ផ្គង់ជីវភាព ។

+ប្រព័ន្ធសេដ្ឋកិច្ចផែនការ (Planned economic system)

-នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចផែនការឬសេដ្ឋកិច្ចបញ្ជា អាជ្ញាធរកណ្តាល(រដ្ឋាភិបាល) គឺជាអ្នកកំណត់ដំណើរការប្រព្រឹត្តិទៅនៃសេដ្ឋកិច្ច និងជាអ្នកធ្វើសេចក្តីសម្រេចចិត្តថាតើត្រូវផលិតអ្វី ? ផលិតយ៉ាងដូចម្តេច? បែងចែក យ៉ាងដូចម្តេច ? នរណាជាអ្នកទទួលយក ?

-ក្នុងប្រព័ន្ធសេដ្ឋកិច្ចបញ្ជា អាជ្ញាធរកណ្តាលតែងតែដាក់ចេញនូវគម្រោងផែនការស្មុគស្មាញ និងមានលក្ខណៈល្អិតល្អន់ក្នុងការប្រព្រឹត្តិទៅនៃខឿនសេដ្ឋកិច្ចជាតិ ។

-ប្រព័ន្ធសេដ្ឋកិច្ចផែនការ ត្រូវបានអនុវត្តន៍ច្រើនកាលពីជាងមួយទស្សវត្សរ៍មុន តែបច្ចុប្បន្ននេះប្រទេសដែលអនុវត្តន៍ប្រព័ន្ធសេដ្ឋកិច្ចផែនការនេះ ដូចជាប្រទេសចិន គុយបា..បានងាកចេញមកអនុវត្តន៍ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារវិញ ។

+ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ (Market economic system)

-ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ជាប្រព័ន្ធសេដ្ឋកិច្ចដែលពឹងផ្អែកលើសិទ្ធិនៃទ្រព្យសម្បត្តិឯកជន និងទីផ្សារដែលនៅក្នុងនោះនីតិបុគ្គលទាំងឡាយជាអ្នកធ្វើសេចក្តីសម្រេចចិត្តថាតើត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្តេច? ផលិតប៉ុន្មាន? ផលិតពេលណា ?

-ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ បុគ្គលទាំងអស់គ្នាត្រូវបានលើកទឹកចិត្តដោយធ្វើតាមចំណង់ចំណូលចិត្តរបស់ពួកគេ និង អាស្រ័យលើទីផ្សារ(តម្រូវការ និង ការផ្គត់ផ្គង់)។

-ការពឹងផ្អែកលើកម្លាំងទីផ្សារមិនមែនមានន័យថា រដ្ឋាភិបាលគ្មានតួនាទីក្នុងការសហការឬធ្វើសេចក្តីសម្រេចចិត្តនៃសេដ្ឋកិច្ចនោះទេ។ កម្លាំងនេះមានឥទ្ធិពលទៅលើរបៀបដែលទីផ្សារដំណើរការយ៉ាងដូចម្តេច?

+ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ (Mixed economic system)

-ជាប្រព័ន្ធសេដ្ឋកិច្ចមួយដែល រដ្ឋនិងឯកជនជាអ្នកដឹកនាំសេដ្ឋកិច្ចដែលបង្ហាញពីអត្តចរិតលក្ខណៈ នៃសេដ្ឋកិច្ចទីផ្សារនិងសេដ្ឋកិច្ចផែនការ ។

-សេដ្ឋកិច្ចចម្រុះ ភាគច្រើនអាចនិយាយបានថា ជាសេដ្ឋកិច្ចទីផ្សារដែលមានការកែតម្រូវនៅលើទីផ្សារព្រមទាំងមានការគាំទ្រពីរដ្ឋាភិបាល ដែលត្រូវបានការពារបរិស្ថាន បទដ្ឋាន សុខុមាលភាពសង្គម និងការពារការប្រកួតប្រជែង ។

ប្រទេសកម្ពុជា មានប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីជាផ្លូវការតាំងពីឆ្នាំ១៩៩៣ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ នៅកម្ពុជាបានបើកឱ្យមានកម្មសិទ្ធិឯកជនភាវូបនីយកម្ម(បង្វែរអ្វីរបស់រដ្ឋជារបស់ឯកជន)មានសហគ្រាសជាច្រើនឱ្យឯកជនកាន់កាប់វិញ។ ទន្ទឹមគ្នានេះដែលរដ្ឋអនុញ្ញតឱ្យមានការធ្វើពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងការវិនិយោគទុនក្រៅប្រទេសផងដែរ។ ក្នុងសេដ្ឋកិច្ចទីផ្សារសេរី មានន័យថាជាកម្មសិទ្ធិទៅលើធនធានសេដ្ឋកិច្ចមួយភាគធំ ដែលស្ថិតក្នុងរង្វង់ការគ្រប់គ្រងរបស់ផ្នែកឯកជនដែលជានិតិបុគ្គល និងរូបវន្តបុគ្គល។ ដោយឡែកនៅក្នុងការគ្រប់គ្រង និងសម្របសម្រួលផ្នែកទាំងស្រុងលើយន្តការនៃទីផ្សារដែលទៅទ្រឹស្តី classic ហៅវាជាសេដ្ឋកិច្ចដែលធ្វើនិយ័តកម្មដោយខ្លួនឯង។ ក្នុងប្រព័ន្ធសេដ្ឋកិច្ចនេះសេដ្ឋកិច្ច សម្រេចចិត្តក្នុងការបែងចែកធនធានជាសេរីភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ។ សេរីភាពនេះអាស្រ័យទៅលើតម្រូវ

ការ និងការផ្គត់ផ្គង់មានន័យថាជាសម្មភាពផលិតកម្ម ការដោះដូរ ការប្រើប្រាស់ទំនិញ និងសេវាទូទៅត្រូវមានសេរីភាពបរិបូរណ៍។ ក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចទីផ្សារសេរីភ្នាក់ងារសេដ្ឋកិច្ចនីមួយៗឱ្យមានការគ្រប់គ្រង់ដោយខ្លួនឯងនូវអត្ថប្រយោជន៍ផ្ទាល់ខ្លួន និងប្រឹងប្រែងធ្វើឱ្យស្ថានភាពអាជីវកម្មរបស់ខ្លួនឱ្យកាន់តែប្រសើរតាមរយៈការប្រកួតប្រជែង។

និយាយរួមសមាសភាគយន្តការមាន៥ គឺកម្មសិទ្ធិឯកជនសេរីភាពក្នុងការជ្រើសរើស អត្ថប្រយោជន៍បុគ្គលការប្រកួតប្រជែងនិងប្រព័ន្ធបង្កើតថ្លៃ[14]។

[14] Wikipedia. (2024, January 10). *ប្រព័ន្ធសេដ្ឋកិច្ច*. Retrieved March, 7 2025, from https://km.m.wikipedia.org/wiki/ប្រព័ន្ធសេដ្ឋកិច្ច

# ជំពូកទី៣

# សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា

## ៣.១ ស្ថានភាពទូទៅរបស់កម្ពុជា

### ៣.១.១ ប្រវត្តិប្រទេសកម្ពុជា

ការមកដល់នៃពួកមហាអំណាចរបស់អាណានិគមអឺរ៉ុបនៅក្នុងសតវត្សទី១៩ ដែលជាពួកមហាអំណាចប្រកបដោយមហិច្ឆិតា និងមានឧត្តមភាពនៃខាងផ្នែកបច្ចេកវិទ្យានាពេលក្រោយមកមានគោលនយោបាយពិតចង់គ្រប់គ្រងពិភពលោកដោយបញ្ចប់នូវពួកសក្តិភូមិក្នុងតំបន់ហើយខណៈនោះ សៀម/ថៃ ទោះបីជាយ៉ាងណាក៏បានបន្ទន់ឥរិយាបថ និងដកថយដើម្បីឱ្យរួចផុតពីគោលនយោបាយនៃអាណានិគមកិច្ចហើយក្លាយខ្លួនទៅជារដ្ឋទ្រនាប់រវាងវៀតណាម/ដាយណាមត្រូវបានក្លាយទៅជាចំណុចប្រសព្វនៃមហិច្ឆតាខាងអាណានិគមនិយមបារាំង។ នៅក្នុងព្រទេសកម្ពុជា ទោះបីជាយ៉ាងណាក៏មិនត្រូវបានគេយកចិត្តទុកដាក់ច្រើនទេតែក៏ត្រូវបានគេដាក់បញ្ចូលទៅក្នុងសហភាពឥណ្ឌូចិនផងដែរ ជាអង្គភាពមួយដែលបានគេទទួលស្គាល់ និងមានសមត្ថភាពបន្ត និងអះអាងអត្តសញ្ញាណ និងបូរណភាពរបស់ខ្លួនកម្ពុជាក៏បានឈានចូលទៅក្នុងទំនើបភាព។ បន្ទាប់ពីមានការស្ងប់សុខនៅក្នុងអាណានិគមមួយរយៈពេល៨០ឆ្នាំមកឧបការណ៍ថារយៈពេលខ្លី នៃការកាន់កាប់របស់ជប៉ុនក្នុងកំឡុងពេលសង្គ្រាមលោកលើកទី២ដែលបានមកព្រមព្រៀងជាមួយគ្នានឹងការប្រគល់អំណាចទៅឱ្យព្រះបាទសីហនុគឺជាការបើកឆាកជំនួសឱ្យ ដំណើរការមិនអាចបកក្រោយមកវិញបានឈានចូលទៅកាន់សម័យកាលនៃប្រវត្តិសាស្ត្រខ្មែរបានរំដោះខ្លួនចេញពីនឹមអាណានិគម និងដើម្បីឆ្ពោះទៅកាន់សម័យកាលប្រវត្តិសាស្ត្រខ្មែរទំនើប។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា (១៩៥៣-៧០) ឱ្យមានឯករាជ្យចាប់តាំងពីឆ្នាំ១៩៥៣ដែលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះសីហនុបានពុះពាររក្សាខ្លួនឱ្យស្ថិតនៅក្នុងអព្យាក្រឹត្យក្នុងពិភពលោកមួយ ដែលបានកំណត់ដោយអក្ខោសានកម្មនៃពួកមហាអំណាចនយស្តិ (នុយក្លេអ៊ែរ) ស.រ.អា. និងសហភាពសូវៀត។ ខណៈនោះសង្គ្រាមឥណ្ឌូចិនរីតតែរីករាលដាលធំឡើងៗ កម្ពុជាបានប្រែឈ្មោះជាសាធារណរដ្ឋខ្មែរដែលជារដ្ឋជាប់ពាក់ព័ន្ធក្នុងសង្គ្រាមដែលកើតចេញមកជាមួយដោយសារហេតុផល តែមួយក្នុងហេតុផលជាច្រើនដែលកើតមានឡើងនៅឆ្នាំ១៩៧០លទ្ធផលផ្សេងមួយទៀតគឺជា សង្គ្រាមរដ្ឋប្បវេណី (សង្គ្រាមគ្នាឯង)។ សង្គ្រាមវៀតណាមបានរីករាលដាលចូលមកកម្ពុជាហើយបណ្តាលឱ្យមានការងើបឡើងនៃពួកខ្មែរក្រហម ពួកគេដណ្តើមយកបានរដ្ឋធានីភ្នំពេញនៅក្នុងឆ្នាំ១៩៧៥ និងបានបន្តយុទ្ធនាការកាប់សម្លាប់មនុស្សជាច្រើន។ ស្ថិតក្នុងកណ្តាប់ដៃរបស់ខ្មែរក្រហម កម្ពុជាដែលបានស្ថិតនៅក្នុងដំណាក់កាលដ៏ខ្មៅងងឹតបំផុតកម្ពុជាប្រជាធិបតេយ្យក៏ជាអង្គហេតុ នៃការបង្កឱ្យមានការកាន់កាប់របស់ប្រទេសវៀតណាមយ៉ាងយូរនៅកម្ពុជា សាធារណរដ្ឋប្រជាមានិតកម្ពុជា និងអាដ្ឋាធរស.ប.ក៏បានធ្វើដំណើរឆ្ពោះទៅដល់សម័យកាលកម្ពុជាទំនើបដែល ចាប់តាំងពីឆ្នាំ១៩៩៣រៀងមកហើយប្រទេសនេះបានទទួលស្គាល់ពីភាពរីកចម្រើននៃខាងផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ហើយក៏ជាពេលដែលត្រូវកសាងប្រទេសឡើងមកវិញពីសង្គ្រាមរដ្ឋប្បវេណីជាច្រើនទសវត្សកន្លងមកដែរ។

## ៣.១.២ គោលនយោបាយ និងចក្ខុវិស័យនៅកម្ពុជា

### ក. គោលនយោបាយ

គោលនយោបាយនៅប្រទេសកម្ពុជា ត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌនៃរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលក្នុងនោះព្រះមហាក្សត្រមានតួនាទីជាប្រមុខរដ្ឋហើយនាយករដ្ឋមន្ត្រីគឺជាប្រមុខរដ្ឋាភិបាល។ នៅក្នុងឆ្នាំ១៩៧៩កងកម្លាំងប្រដាប់អាវុធវៀតណាមបានវាយលុកចូលទឹកដីកម្ពុជារួចបានផ្តួលរលំរបបកម្ពុជាប្រជាធិបតេយ្យហើយបន្ទាប់មកក៏បានបន្តឈរជើងនៅក្នុងប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៨៩។ បន្ទាប់ពីការដួលរលំនៃរបបកុម្មុយនីស្តនៅជុំវិញពិភពលោកចាប់តាំងពីឆ្នាំ ១៩៩០ ទីបំផុតវៀតណាមក៏បានសម្រេចចិត្តដកកងកម្លាំងរបស់ខ្លួនចេញពីដែនដីកម្ពុជា។ រដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើបន្ទាប់ពីភាគីជម្លោះបានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ ១៩៩១ និងបន្ទាប់ពីមានការបោះឆ្នោតដែលបានរៀបចំឡើងដោយអាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់)។ រដ្ឋធម្មនុញ្ញនេះបានប្រកាសអំពីលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅក្នុងប្រទេសកម្ពុជាហើយក៏មានអំណាចធំៗបីគឺ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ និងអំណាចនីតិប្បញ្ញត្តិ។ ក៏ប៉ុន្តែចាប់តាំងពីបានប្រកាសរដ្ឋធម្មនុញ្ញមកកម្ពុជាគឺមិនដែលមានបក្សប្រឆាំងណាដែលមានសក្តានុភាពអាចយកឈ្នះ ទៅលើបក្សកាន់អំណាចនោះឡើយដោយហេតុនេះហើយទើបសម្តេចហ៊ុន សែនអាចបន្តកាន់អំណាចជានាយករដ្ឋមន្ត្រីគិតចាប់តាំងពីឆ្នាំ១៩៨៥ មក។ គណបក្សសម្តេចគឺ គណបក្សប្រជាជនកម្ពុជាដែលដណ្តើមអាសនៈបានទាំង ១២៥ នៅក្នុងស្ថាប័នរដ្ឋសភាក្នុងឆ្នាំ២០១៨ បន្ទាប់ពីបានរំលាយគណបក្សសង្គ្រោះជាតិកម្ពុជាចោល ដែលពេលនោះត្រូវជាបក្សប្រឆាំងធំបំផុតនឹងបក្សប្រជាជន។ តមកទៀតរដ្ឋធម្មនុញ្ញក៏បានធ្វើការប្រកាសដែលថាប្រទេសកម្ពុជាគឺជា "រដ្ឋឯករាជ្យអធិបតេយ្យសន្តិភាពអព្យាក្រឹត និងរដ្ឋមិនចូលបក្សសម្ព័ន្ធ។

អំណាចនីតិប្រតិបត្តិត្រូវបានធ្វើការអនុវត្តដោយរាជរដ្ឋាភិបាលក្នុងនាម និងដោយឯកច្ឆន្ទពីសំណាក់ព្រះមហាក្សត្រ។ រដ្ឋាភិបាលត្រូវបានគេបង្កើតឡើងដោយគណៈរដ្ឋមន្ត្រីដែលដឹកនាំដោយនាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីត្រូវបានជួយឬ គាំទ្រដោយសមាជិកនៃក្រុមប្រឹក្សានោះមានដូចជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីជាន់ខ្ពស់ និងរដ្ឋមន្ត្រីផ្សេងៗទៀត។ អំណាចនីតិប្បញ្ញត្តិត្រូវបានផ្ទេរទៅនីតិបញ្ញត្តិទ្វេភាគី ដោយក្នុងនោះមានរដ្ឋសភា ដែលមានសិទ្ធិអំណាចបោះឆ្នោតទៅលើសេចក្តីព្រមព្រាងច្បាប់ហើយព្រឹទ្ធសភាវិញមានសិទ្ធិអំណាចពិនិត្យមើលឡើងវិញ។ នៅពេលដែលអនុម័តច្បាប់តាមរយៈស្ថាប័នសភាទាំងពីរសេចក្តីព្រមព្រាងច្បាប់នោះនឹងត្រូវដាក់ជូនព្រះមហាក្សត្រដើម្បីឡាយព្រះហត្ថលេខា និងប្រកាសឱ្យប្រើប្រាស់។ អំណាចនៃតុលាការឱ្យមានភារកិច្ចការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងដោះស្រាយជម្លោះវិវាទដោយមិនមានលម្អៀង។ តុលាការកំពូល គឺជាតុលាការខ្ពស់បំផុតនៅក្នុងប្រទេស ហើយមានអំណាចវិនិច្ឆ័យលើសេចក្តីសម្រេចរបស់តុលាការជាន់ទាប។ ស្ថាប័នដាច់ដោយឡែកមួយដែលទៀតហៅថា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបកស្រាយអំពីរដ្ឋធម្មនុញ្ញ និងច្បាប់ហើយដើម្បីដោះស្រាយរាល់នូវវិវាទទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងសមាជិកសភា។

គណបក្សប្រជាជនកម្ពុជា បានគ្រប់ដណ្តប់លើទិដ្ឋភាពនយោបាយកម្ពុជាចាប់តាំងពីជម្លោះប្រដាប់អាវុធនៃឆ្នាំ១៩៩៧ នៅឯទីក្រុងភ្នំពេញបានបញ្ចប់មកម្លេះ។ នៅគណបក្សផ្សេងៗទៀតដែលជាគូប្រជែងនឹង

បក្សប្រជាជនកម្ពុជាមាន គណបក្សហ៊្វុនស៊ិនប៉ិចដែលជាគណបក្សរាជានិយម និងជាអតីតគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយចោលដោយតុលាការកំពូលនៅក្នុងឆ្នាំ២០១៧។ អ្នកវិទ្យាសាស្ត្រនយោបាយឈ្មោះ ស៊្ទីវិនឡេវីតស្គី និងលូកាន-វេ បានពណ៌នាពីប្រទេសកម្ពុជាថាជា"របបផ្តាច់ការប្រកួតប្រជែង" ដែលជាប្រភេទរបបចម្រុះ មានលក្ខណៈជាប្រជាធិបតេយ្យផងនិងបែបផ្តាច់ការផង។

**ខ. ចក្ខុវិស័យនៅកម្ពុជា**

កម្ពុជាមានចក្ខុវិស័យសេដ្ឋកិច្ចមួយ ដែលជំរុញឱ្យមានការផ្តល់ឱកាសសម្រាប់ប្រជាពលរដ្ឋទាំងអស់ក្នុងការចូលរួម ក៏ដូចជាឱកាសក្នុងការទទួលបានអត្ថប្រយោជន៍ត្រឡប់មកពីភាពរីកចម្រើនរបស់ប្រទេសជាតិវិញផងដែរ។ ជាមួយគ្នានេះដែរ ស្នូលគន្លឹះនៃចក្ខុវិស័យនេះផ្ទាល់ គឺការផ្តោតទៅកាន់សេដ្ឋកិច្ចចម្រុះដែលផ្តល់អាទិភាពដល់ការអនុវត្ត ដែលប្រកបដោយនិរន្តរភាព ការប្រើប្រាស់ឬ ច្នៃប្រឌិតបច្ចេកវិទ្យា និងការជំរុញគាំទ្រទៅកាន់សហគ្រាសធុនតូច និងមធ្យម (SMEs) ជាដើម។ គួរឱ្យកត់សម្គាល់ផងដែរថាការអភិវឌ្ឍទៅលើវិស័យសំខាន់ៗដូចជា កសិកម្ម ផលិតកម្ម និងទេសចរណ៍ក៏ជាបុព្វហេតុដែលពង្រឹងឱ្យមូលដ្ឋានគ្រឹះដ៏រឹងមាំនៅក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាដើម្បីឆ្ពោះទៅកាន់គោលដៅ SDGs ផងដែរ ។

ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខកម្ពុជាគួរណាតែប្រើប្រាស់វិធីសាស្ត្រសេដ្ឋកិច្ចពហុភាគី។ ក្នុងវិធីសាស្ត្រមួយនេះមានមុខងារក្នុងការជំរុញសហគ្រិនភាព និងផ្តល់នូវហិរញ្ញវត្ថុដើមទុន សម្រាប់ការចាប់ផ្តើមអាជីវកម្ម និងសហគ្រាសធុនតូច និងមធ្យម ដែលនឹងជំរុញការបង្កើតផលិតកម្ម និងឱកាសការងារផងដែរ។ ម្យ៉ាងវិញទៀតរាជរដ្ឋាភិបាលក៏អាចសហការជាមួយនឹងគ្រឹះស្ថានឯកជនដើម្បីបង្កើតឱ្យមានបរិយាកាសទីផ្សារមួយដែលជំរុញឱ្យមានសកម្មភាពអាហារ័ណ និហរ័ណ ពាណិជ្ជកម្ម ក៏ដូចជាការវិនិយោគ ពីវិនិយោគិន ទាំងក្នុងស្រុក និងក្រៅស្រុក។

លើសពីនេះទៅទៀត ដើម្បីជំរុញឱ្យសេដ្ឋកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពកម្ពុជាគួរបន្តការវិនិយោគទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាបណ្តាញដឹកជញ្ជូន នៃការតភ្ជាប់បណ្តាញឌីជីថលឱ្យបានកាន់តែទូលំទូលាយថែមទៀតផង។ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថលនេះនឹងផ្តល់ជាឱកាសទៅដល់សហគមន៍ជនបទនៅក្នុងការចូលរួមដំណើរការសេដ្ឋកិច្ចទំនើបដែលកំពុងអភិវឌ្ឍនេះផងដែរ។ ចំណុចសំខាន់មួយទៀតដើម្បីសម្រេចបាននូវគោលដៅសេដ្ឋកិច្ច គឺផ្តោតទៅលើការងារសមរម្យមួយសម្រាប់ប្រជាជនគ្រប់រូប។ នៅក្នុងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ត្រូវតែដើរទន្ទឹមគ្នាជាមួយ នឹងការការពារសិទ្ធិកម្មករ និងលើកកម្ពស់ប្រាក់ឈ្នួលដែលសមស្របទៅនឹងផលិតភាពរបស់កម្មករគ្រប់រូប។ ទន្ទឹមនឹងនេះដែរ ស្ថាប័ននានា គួរតែពង្រីកឱកាសក្នុងការបណ្តុះបណ្តាលជំនាញ និងការអប់រំវិជ្ជាជីវៈទៅដល់និយោជិតជាពិសេសយុវជនដើម្បីបង្កើនឱកាសទទួលបានការងារសមរម្យ និងស្របតាមតម្រូវការទីផ្សារ។

បន្ថែមពីនេះការលើកកម្ពស់ និងផ្តល់សិទ្ធស្មើគ្នារវាង បុរស ស្ត្រី និងបុគ្គលគ្រប់លក្ខណៈនឹងមិនត្រឹមតែលើកកម្ពស់កំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេប៉ុន្តែថែមទាំងជំរុញ ឱ្យមានសង្គមការងារមួយដែលមានសមភាពយេនឌ័រ និងមិនមានការរើសអើងផងដែរ។

## ៣.២ កត្តានៃការវិនិយោគលើវិស័យអចលនទ្រព្យមានការរីចម្រើន

សព្វថ្ងៃនេះយើងសង្កេតឃើញ ថាវិស័យអចលនទ្រព្យមានការរីកចម្រើនខ្ពស់គួរឱ្យកត់សម្គាល់ដោយផ្អែកទៅលើកត្តាមួយចំនួនដូចខាងក្រោម៖

### ៣.២.១ កត្តាសេដ្ឋកិច្ច

យើងសំដៅទៅលើប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ បើកាលណាប្រជាពលរដ្ឋមានប្រាក់ចំណូលខ្ពស់ នោះកំណើនសេដ្ឋកិច្ចក៏កាន់តែខ្ពស់ ហើយអត្រាប្រជាពលរដ្ឋដែលមានការងារធ្វើក៏កាន់តែច្រើន ដែលអាចឱ្យប្រជាពលរដ្ឋសល់ប្រាក់ និងគិតដល់ការវិនិយោគលើវិស័យអចលនទ្រព្យ ដើម្បីទទួលបាននៃប្រាក់ចំណេញមកវិញ។ ក្នុងនោះក៏ជួយបានជំរុញឱ្យវិស័យដែលពាក់ព័ន្ធមានការរីកចម្រើនផងដែរ។ ទាំងអស់នេះហើយបានធ្វើឱ្យវិស័យអចលនទ្រព្យមានតម្រូវការពីសំណាក់ ប្រជាពលរដ្ឋជាពិសេសគឺនៅលំនៅដ្ឋាន។ ជាការពិតណាស់ វិស័យមួយនេះមិនរីកចម្រើនទៅមុខបាន លុះត្រាតែលែងមានតម្រូវការ។

ជាក់ស្តែង បើតាមរបាយការណ៍របស់ធនាគារពិភពលោកនៅកម្ពុជា នៅក្នុងឆ្នាំ២០២០ វិបត្តិដែលបង្កដោយជំងឺកូវីដ១៩ បានជះឥទ្ធិពលយ៉ាងអាក្រក់ទៅលើផ្នែកធំៗទាំងបីនៃសេដ្ឋកិច្ចរបស់កម្ពុជា ដូចជាវិស័យទេសចរណ៍, ការនាំចេញនៃកម្មន្តកម្ម, និងវិស័យសំណង់។ វិស័យទាំងបីនេះ បានរួមគ្នាមានចំណែកជាង ៧០ ភាគរយនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស និងផ្តល់ការងារបានចំនួន៣៩ភាគរយនៃការងារមានប្រាក់ឈ្នួលទាំងអស់ក្នុងប្រទេស នៅក្នុងឆ្នាំ២០១៩។ នៅក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចមានកំណើនអវិជ្ជមានក្នុងអត្រា ៣,១ ភាគរយ ដែលជាកំណត់ត្រាដ៏អាក្រក់បំផុតតាំងពីឆ្នាំ១៩៩៤ មក។ ហេតុដូចនេះ អត្រាតម្រូវការអចលនទ្រព្យរបស់ប្រពលរដ្ឋមានការធ្លាក់ចុះ ដែលធ្វើឱ្យវិស័យមួយនេះមានការជាប់គាំងផងដែរ។

### ៣.២.២ កត្តាវិនិយោគដោយផ្ទាល់ពីបរទេស

ការវិនិយោគដោយផ្ទាល់ពីបរទេស គឺជាការវិនិយោគមួយដែលបង្កើតឡើងដោយម្ចាស់សហគ្រាសឬវិនិយោគិនដែលមិនមែននៅក្នុងស្រុកឬ សហការជាមួយសហគ្រាសនៅក្នុងស្រុកនៃក្រោមការគ្រប់គ្រងដោយជនបរទេស។ ច្បាប់វិនិយោគនៅក្នុងប្រទេសកម្ពុជាមានភាពងាយស្រួលដល់ អ្នកវិនិយោគិនបរទេស ហើយកម្ពុជាមានច្បាប់អនុគ្រោះពន្ធច្រើនជាងគេនិងជាប្រទេសមាន ទីផ្សារសេរីផងដែរ។

បើតាមឱ្យដឹងពីរបាយការណ៍នៅប្រចាំនៅឆ្នាំ២០១៩របស់ធនាគារជាតិនៃកម្ពុជាប្រទេសចិនបាននៅឈរក្នុងលំដាប់ទី១ដែលបានធ្វើការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា។ ទុនវិនិយោគដែលមានប្រមាណជាង ១ពាន់៣លានរៀលនាំ មុខប្រទេសធំៗចំនួន៤ផ្សេងទៀតដែលកំពុងធ្វើការវិនិយោគលើវិស័យនេះ។ វិនិយោគដែលមកពីបណ្តាប្រទេសផ្សេងៗ ទៀតមានដូចជា សិង្ហបុរី អាមេរិក កូរ៉េខាងត្បូង ជប៉ុន និងប្រទេសផ្សេងៗទៀត។

### ៣.២.៣ កត្តាសន្តិភាព និងស្ថិរភាពនយោបាយ

ស្ថិរភាពនយោបាយ គឺជារឿងដ៏សំខាន់នៅក្នុងការជួយទៅដល់ការអភិវឌ្ឍប្រទេសឱ្យកាន់តែមានភាពរីកចម្រើន។ បើកាលណាប្រទេសមួយគ្មានស្ថេរភាពនយោបាយនោះទេកុំថាឡើយចង់ឱ្យវិស័យអចលនទ្រព្យរីកចម្រើន សន្តិភាពក៏គ្មានដែរ ហើយវិស័យដ៏ទៃផ្សេងទៀតក៏ត្រូវធ្លាក់ចុះដូចគ្នាដែរ។ កម្ពុជាបានឆ្លងកាត់នូវភ្លើងសង្គ្រាម និងឧបសគ្គគ្រប់បែបយ៉ាងអស់រយៈពេលជាច្រើនឆ្នាំ ហើយត្រូវបានធ្វើការទប់ស្កាត់រាល់អស្ថិរ

ភាពនយោបាយឬ ការញុះញង់ណាមួយដែលជាការបង្កឱ្យមានភាពចលាចលនៅក្នុងសង្គមជាតិកម្ពុជា។ កត្តាសន្តិភាព និងស្ថិរភាពនយោបាយបានធ្វើជាមូលដ្ឋានគ្រឹះ ដ៏រឹងមាំនៃដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាឱ្យសម្រេចបាននូវកំណើនខ្ពស់ប្រមាណ ៧,១ភាគរយ នៅក្នុងឆ្នាំ២០១៨។ អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងអន្តរជាតិបន្តកើនឡើង។

ហេតុដូចនេះ កម្ពុជាជាមូលដ្ឋានដ៏សំខាន់ផងដែលនៅក្នុងការទាក់ទាញការវិនិយោគពីបរទេស ដែលបានធ្វើឱ្យ កម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មីនៅលើឆាកអន្តរជាតិ ហើយស្ថិតនៅក្នុងក្រសែភ្នែក ឬគោលដៅរបស់អ្នកវិនិយោគអន្តរជាតិ ឱ្យមកវិនិយោគនៅកម្ពុជាលើវិស័យអចលនទ្រព្យ ដូចជា គម្រោងលំនៅឋាន ខុនដូរ អាគារការិយាល័យជាដើម។

## ៣.៣ សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យសេដ្ឋកិច្ចនៅកម្ពុជា

ការវិនិយោគមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ ទៅដល់សេដ្ឋកិច្ចជាតិនៃប្រទេសមួយដែលកំពុងតែមានការអភិវឌ្ឍក៏ដូចជាប្រទេសអភិវឌ្ឍន៍ដែរ។ ក្នុងវិស័យឯកជនត្រូវបានចាត់ទុកទៅលើការវិនិយោគយ៉ាងសំខាន់ ជាមួយវិស័យសាធារណៈក្នុងការអភិវឌ្ឍលើគ្រប់វិស័យ ក្នុងគោលបំណងលើកស្ទួយដល់ សេដ្ឋកិច្ចជាតិឱ្យបានរីកចម្រើនជាបន្តបន្ទាប់។ ម្យ៉ាងវិញទៀត សារៈសំខាន់នៃការវិនិយោគនេះបានជួយផ្តល់ការងារដល់ ពលរដ្ឋខ្មែរគ្រប់រូបនិងជួយលើកតម្កើន ជីវភាពពលរដ្ឋក្រីក្រដើម្បីឱ្យមាន ជីវភាពធុំធ្វើនដូចប្រទេសក្នុងពិភពលោកនាពេលបច្ចុប្បន្នដូចជាប្រទេស សឹង្ហបូរីជាដើម។ ការវិនិយោគជាប្រតិបត្តិការប្រើប្រាស់នូវឧបករណ៍គតិយុត្ត ដើម្បីធ្វើឱ្យសេដ្ឋកិច្ចក្នុងសង្គមដំណើរការបានល្អ។ វាអាចជាការបង្កើតឡើងតាមរយៈប្រើប្រាស់ទុន ឬភាគហ៊ុនដែលជាដើមទុនសម្រាប់បង្កើតគ្រោងសេដ្ឋកិច្ច ដែលបានផ្តល់ឱ្យអ្នកវិនិយោគទុនបានទទួលនូវផលចំណេញក្នុងគម្រោងរបស់អ្នកវិនិយោគទាំងនោះ។

ដើម្បីធ្វើឱ្យសេដ្ឋកិច្ចនៃប្រទេសនីមួយៗមានការអភិវឌ្ឍឡើងខ្លាំង គឺយើងត្រូវមានការចូលរួមទៅលើគ្រប់វិស័យទាំងអស់ដូចជា វិស័យកសិកម្ម ឧស្សាហកម្ម ការវិនិយោគលើវិស័យអចលនទ្រព្យ។ល។ បើយើងនិយាយពីការវិនិយោគលើវិស័យអចលនទ្រព្យវិញ គឺឃើញថាមានសន្ទុះខ្លាំងមែនទែននៅក្នុងប្រទេសកម្ពុជាយើងតាមរយៈសំណង់អគារ ទាំងការស្នាក់នៅ និងសម្រាប់ប្រកបមុខរបរដែលកំពុងសាងសង់ជារៀងរាល់ថ្ងៃ ហើយមនុស្សក៏សម្រុកទិញ កាន់តែច្រើនឡើងៗ។ តើលោកអ្នកដឹងទេថា ក្រៅពីការទទួលបានគេហដ្ឋានសម្រាប់ស្នាក់នៅ ទីកន្លែងដើម្បីលក់ដូរ ទុកវិនិយោគលក់ឬជួល តើការវិនិយោគអចលនទ្រព្យទាំងនោះ មានផលប្រយោជន៍អ្វីខ្លះទៀតចំពោះសង្គមជាតិ?

### ៣.៣.១ វិស័យអចលនទ្រព្យ

វិស័យអចលនទ្រព្យ បានចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាដូចជា៖

- បង្កើនការងារ មុខរបរ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋ
- កាត់បន្ថយចំណាក់ស្រុកទៅក្រៅប្រទេស ដែលជាមូលហេតុធ្វើឱ្យកម្ពុជាខ្វះខាតកម្លាំងពលកម្ម
- កាត់បន្ថយភាពក្រីក្រ និងអត្រាគ្មានការងារធ្វើ
- ជំរុញការវិនិយោគ និងទុនវិនិយោគក្នុងប្រទេស
- បង្កើនចំណូលពន្ធដារ ពន្ធគយ និងជួយរុញច្រានឱ្យមានកំណើនសេដ្ឋកិច្ច
- លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ទីប្រជុំជន និងជនបទ

- ជួយកសាងសមត្ថភាពបុគ្គលិក ក៏ដូចជាមន្ត្រី ដែលទទួលបន្ទុកការងារនេះ
- សម្រេចបាននូវគោលនយោបាយជាតិស្តីពីលំនៅឋាន របស់រាជរដ្ឋាភិបាល
- ប្រជាពលរដ្ឋមានលទ្ធភាព ទទួលបានលំនៅឋានរស់នៅផ្ទាល់ខ្លួនដោយសមរម្យ និងស្របច្បាប់

### ៣.៣.២ ការវិនិយោគអចលនទ្រព្យ

ការវិនិយោគអចលនទ្រព្យមានផលប្រយោជន៍ចំពោះសង្គមជាតិដូចជា៖

**ក.ជួយទប់ទល់ផលប៉ះពាល់ពីអតិផរណា**

អតិផរណា(Inflation)ជាការកើនឡើងនៃកម្រិតថ្លៃជាទូទៅរបស់ទំនិញ និងសេវានៅក្នុងប្រទេស ឬតំបន់រឹង ប្រាក់ត្រូវបានចុះថោកក្នុងកំឡុងពេលណាមួយ។ បានសេចក្តីថាបើអ្នកចង់ទិញរបស់អ្វីមួយក្នុងពេលមានអតិផរណា គឺត្រូវចំណាយប្រាក់ច្រើនជាងមុនដើម្បីទិញបានរបស់នោះ។ ចំពោះអចលនទ្រព្យវិញនឹងត្រូវបានចាត់ទុកជាប្រភេទទ្រព្យដែលអាចជួយទប់ទល់នឹងកំណើនអតិផរណានេះ។ ឧទាហរណ៍ប្រសិនបើឥឡូវអ្នកកំពុងតែមានអចលនទ្រព្យផ្ទះ ដែលប្រើកម្ចីពីធនាគារតាមរយៈការបង់ត្រឡប់ថេរនោះឥទ្ធិពលនៃកំណើនអតិផរណា ក៏មិនបានផ្តល់ផលប៉ះពាល់អាក្រក់ដល់ការវិនិយោគនេះដែល ព្រោះថាតម្លៃផ្ទះអាចនឹងកើនឡើង ចំណែកឯការសងត្រឡប់ទៅធនាគារវិញគឺនៅតែរក្សាក្នុងទំហំទឹកប្រាក់ដដែរ។ ចំពោះអ្នកដែលបានដាក់នៃអចលនទ្រព្យសម្រាប់ជួល គឺអាចតម្លើងថ្លៃឈ្នួលស្របទៅតាមកំណើនអតិផរណា ហើយចំណូលដែលបានមកពីការតម្លើងថ្លៃជួលនេះទៀតសោត គឺរួមចំណែកទប់ទល់ក្នុងការប្រើប្រាស់ការចំណាយផ្សេងៗដែលបានឡើងថ្លៃក្នុងពេលជាមួយគ្នាដែរ។

**ខ.បង្កើនទីផ្សារការងារ**

ការវិនិយោគអចលនទ្រព្យមានការរីកចម្រើនយ៉ាងខ្លាំង ក៏បានធ្វើឱ្យវិសាលភាពនៃទីផ្សារការងារក្នុងវិស័យនេះឱ្យកាន់តែទូលំទូលាយ ហើយប្រជាពលរដ្ឋជាច្រើនជាពិសេសយុវជនក៏ទទួលបានការងារធ្វើដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ សម្រាប់ជីវភាពបានកាន់តែច្រើន។របាយការណ៍អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩បានឱ្យដឹងថា សកម្មភាព ក្នុងវិស័យអចលនទ្រព្យបានបង្កើតឱកាសការងារដល់ ពលរដ្ឋប្រមាណ២៥,០០០នាក់ នៃចំនួនប្រជាជនមានការងារធ្វើសរុបទូទាំងប្រទេស។ សកម្មភាពការងារនៅក្នុងវិស័យអចលនទ្រព្យ ត្រូវបានបែងចែកទៅតាមប្រភេទ ផ្សេងៗគ្នាដូចជា ផ្នែកបម្រើសេវាកម្មទិញលក់នឹងជួល(ភ្នាក់ងារអចលនទ្រព្យ) ផ្នែកវាយតម្លៃនឹងការគ្រប់គ្រងអចលនទ្រព្យ(property management)បុគ្គលិកបម្រើការនៅក្នុងក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ (real estate developer) អ្នកគួកជេរ។ល។ ពួកយើងអាចនិយាយបានថាការងារផ្នែកសាងសង់ដូចជា ជាងសំណង់ វិស្វករ ស្ថាបត្យករក៏ជាផ្នែកមួយនៃការងារក្នុងវិស័យអចលនទ្រព្យដែរ។ ជារួមកាលណាប្រជាពលរដ្ឋមានការងារធ្វើគ្រប់គ្រាន់ជីវភាពធូរធារនោះសេដ្ឋកិច្ចជាតិនឹងមានការរីកចម្រើន។

**គ.កែប្រែមុខមាត់តំបន់ដែលមានការអភិវឌ្ឍតិចតួច**

នៅពេលមានការវិនិយោគអចលនទ្រព្យនោះមនុស្សត្រូវការប្រាក់ដើម្បីទិញ ឬបង់រំលស់យកផ្ទះសម្បែង តាម តម្រូវការរៀងៗខ្លួន។ ដូចនេះហើយចំពោះអ្នកដែលមិនទាន់មានប្រាក់គ្រប់គ្រាន់គឺប្រាកដជាជ្រើសយក ការខ្ចីប្រាក់ ធនាគារ បញ្ចាំទ្រព្យនឹងសងវិញជាការប្រាក់តាមពេលវេលាកំណត់ប្រចាំខែ។ នៅពេលមានអ្នកខ្ចី ប្រាក់ពីស្ថាប័ន ហិរញ្ញវត្ថុដែលមានដូចជាៈ ធនាគារស្ថាប័នមីក្រូហិរញ្ញវត្ថុ កាន់តែច្រើននោះវិស័យធនាគារ និង ហិរញ្ញវត្ថុទាំងនោះ ក៏អាចបង្កើនទ្រព្យសកម្មបានច្រើនដូចគ្នា។ ជាក់ស្តែងតាមរបាយការណ៍ត្រួតពិនិត្យរបស់ ធនាគារជាតិនៃកម្ពុជានៅក្នុងឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញថាៈ ធនាគារបានផ្តល់នូវប្រាក់កម្ចីដើម្បីទិញផ្ទះ ជាកម្មសិទ្ធិផ្ទាល់ខ្លួនចំនួន១១.៤ភាគរយ និងការជួញដូរនៃអចលនទ្រព្យ៨.៤ភាគរយ នៃឥណទានរបស់ អតិថិជនសរុបចំនួន១០២.៥ទ្រីលានរៀល។ កត្តាដែលជម្រុញឱ្យមានការរួមចំណែកដល់ទ្រព្យសកម្មរបស់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានកើនឡើងដល់២០៩.៤ ទ្រីលានរៀល។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

ការអភិវឌ្ឍអចលនទ្រព្យនៅកម្ពុជាឱ្យមានការរីកចម្រើនខ្លាំង នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចទាំងមូលរបស់ប្រទេស។ នៅក្នុងការគ្រប់គ្រងអចលនទ្រព្យដែលមានប្រសិទ្ធិភាព ដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីករបៀបរស់នៅឱ្យបានច្រើនបំផុតតំបន់រួមអចលនទ្រព្យ និងសោភ័ណភាពជុំវិញ។ នៅក្នុងការគ្រប់គ្រងទៅលើអចលនទ្រព្យ ដែលទាក់ទងនឹងការសំអាតសន្តិសុខការជានារ៉ាប់រង និងគណនេយ្យសម្រាប់អគារសហកម្មសិទ្ធិ ឬការអភិវឌ្ឍកំពុងមានសារៈសំខាន់កាន់តែខ្លាំងឡើងសម្រាប់វិស័យអចលនទ្រព្យដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា។

- បង្កើតឱ្យមានការងារធ្វើនៅពេលមានការវិនិយោគច្រើនក្រុមហ៊ុនវិនិយោគទាំងនោះត្រូវការជ្រើសរើសបុគ្គលិកដើម្បីធ្វើការ ជាហេតុធ្វើឱ្យឱកាសការងារមានកាន់តែច្រើន
- ចំណូលពន្ធកើនឡើងប្រភពនៃចំណូលពន្ធមានពន្ធលើប្រាក់បៀវត្សរ៍ពន្ធលើប្រាក់ចំណេញ ពន្ធកាត់ទុក អាករពិសេសដែលប្រភពនៃចំណូលទាំងនេះគឺបានមកពីក្រុមហ៊ុនសហគ្រាស កម្មករ និយោជិត អ្នកប្រើប្រាស់។ កាលណាមានវិនិយោគធ្វើឱ្យចំនួនក្រុមហ៊ុនមានការកើនឡើង ធ្វើឱ្យការប្រមូលពន្ធមានការកើនឡើង
- សេដ្ឋកិច្ចកើនឡើង កាលណាការវិនិយោគកើនឡើងធ្វើឱ្យ GDP កើនឡើងដោយយោងលើរូបមន្តក្នុងគណនា (GDP = C+I+G+NX)។ នៅពេលដែល GDP មានការកើនឡើងធ្វើឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើន
- អ្នកវិនិយោគគិន មានការចាប់អារម្មណ៍មកបណ្តាក់ទុនជាច្រើននឹងប្រជាជនមានការយល់ដឹងច្បាស់ទើបមានវិស័យមួយនេះកើតឡើង
- ប្រជាពលរដ្ឋដែលមានជីវភាពមធ្យមក៏អាច វិនិយោគលើវិស័យអចលនទ្រព្យបានតាមរយៈការទិញដីធ្លី ក្នុងតម្លៃទាប ហើយលក់ចេញវិញក្នុងតម្លៃទីផ្សារជាក់ស្តែង

## ៤.២ ការវិភាគលើចំណុចខ្សោយ

តាមរយៈលើការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំកន្លងមកឱ្យបានឃើញថា ការវិនិយោគលើវិស័យអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា ហើយក៏មានចំណុចខ្សោយមួយចំនួនដែលត្រូវយកចិត្តទុកដាក់កែលម្អ និងពង្រឹងឡើងវិញដើម្បីឱ្យប្រទេសជាតិកាន់តែទទួលបានភាពល្អប្រសើរជាងនេះមានដូចខាងក្រោម៖

- សេដ្ឋកិច្ចធ្លាក់ចុះធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យអចលនទ្រព្យ ប្រជាពលរដ្ឋគ្មានលទ្ធភាពទិញ ឯអ្នកខ្លះវិញក៏សម្រេចចិត្តលក់អចលទ្រព្យភ្លាមៗដោយមិនទទួលបានប្រាក់ចំណេញ ឬអាចនឹងខាតក៏ថាបាន។
- ធនាគារបានតម្លើងអត្រាការប្រាក់ក្នុងការកម្ចី ដែលធ្វើឱ្យប៉ះពាល់ខ្លាំងលើវិស័យអចលនទ្រព្យដែលធ្វើឱ្យអ្នកវិនិយោគមិនមានលទ្ធភាពក្នុងការកម្ចីប្រាក់ទៅវិនិយោគព្រោះវិស័យនេះត្រូវប្រើរយៈពេលយូរ។

- ជាទូទៅអ្នកវិនិយោគមិនទាន់ដឹងច្បាស់អំពីប្រភេទនៃអចលនទ្រព្យនោះទេ ហើយពួកគេតែងតែគិតថាអចលនទ្រព្យនេះជាទ្រព្យសកម្មរយៈពេលខ្លីហើយលក់ចេញបានភ្លាមៗតែការពិតវាជាទ្រព្យសកម្មរយៈពេលវែង។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្នុងនាមក្រុមនាងខ្ញុំ ជានិស្សិតដែលសរសេរសារណាបញ្ចប់ការសិក្សា ដែលសរសេរស្តីពី«សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា» បានឱ្យមើលឃើញថាវិស័យលើអចលនទ្រព្យគ្រប់ប្រភេទពិតជាដើរតួរយ៉ាងសំខាន់សម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជា ក្នុងការបង្កើតនៃចំណូលដែលជាប្រយោជន៍ដល់ថវិការជាតិ។ មិនត្រឹមតែប៉ុណ្ណោះ វិស័យមួយនេះក៏បានជួយទៅដល់សេដ្ឋកិច្ចសង្គមកិច្ចតាមរយៈ ការជួយឱ្យប្រជាពលរដ្ឋមានការងារធ្វើមានមុខរបររកស៊ីដែលជា ចំណែកមួយក្នុងការកាត់បន្ថយភាពក្រីក្រ។ លើសពីនេះទៅទៀតវិស័យមួយនេះក៏បានជួយឱ្យ GDP ប្រទេសមានការកើនឡើងថែមមួយកម្រិតដែលលធ្វើអោយសង្គមមានភាពរីកចម្រើន ទៅតាមរយៈការអ្នកវិនិយោគិនពីក្រៅស្រុកមកធ្វើការបណ្តាក់ទុនរកស៊ីដែលបង្កើតឱ្យមានអគារធំៗនៅក្នុងស្រុក។ ម្យ៉ាងវិញទៀតវិស័យនេះទៀតសោតបានជួយលើកកម្ពស់ទៅដល់ហេដ្ឋារចនាសម្ព័ន្ធកែប្រែមុខមាត់តំបន់ព្រមទាំងជួយទៅដល់ការទប់ទល់អតិផរណា។ ជាពិសេសជាងនេះទៅទៀតនោះគឺជាការវិនិយោគលើអចលនទ្រព្យដែលបានផ្តល់នូវផលចំណេញ និងប្រាក់ចំណូលឱ្យអ្នកវិនិយោគច្រើននៅថ្ងៃអនាគតដោយសារតែអចលនទ្រព្យអាចកើនតម្លៃខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយអាចទទួលបានចំណូលពីការដាក់ជួលជារៀងរាល់ខែ ដែលជាចំណែកមួយនៃប្រភពចំណូល បន្ថែមទៀតជាហេតុដែលធ្វើឱ្យវិស័យនៃអចលនទ្រព្យមួយនេះជាជម្រើសដ៏ល្អនៅក្នុងការវិនិយោគរយៈពេលវែង។

ជាការពិតណាស់វិស័យអចលនទ្រព្យពិតជាដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ ដូចនេះក្នុងនាមយើងជាអ្នកវិនិយោគត្រូវយកចិត្តទុកដាក់ខ្លាំង ដើម្បីឱ្យវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជាមានរីកចម្រើនឱ្យកាន់តែខ្លាំងជាងមុន ហើយលោកអ្នកគួរសាកល្បងធ្វើការវិនិយោគឬបម្រើការងារនៅក្នុងវិស័យនេះដើម្បីទទួលបាន នូវផលប្រយោជន៍ជាច្រើនឥតគណនា។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានសិក្សា និងការស្រាវជ្រាវស្តីពី សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា″ ក្រុមនាងខ្ញុំមើលឃើញនូវចំណុចខ្វះខាតមួយចំនួន ដូច្នេះក្រុមនាងខ្ញុំសូមធ្វើការបញ្ចេញមតិមួយចំនួនស្តីពីការបន្ថែមយុទ្ធសាស្ត្របង្កើនចំណូលជាតិឱ្យកាន់តែកើនឡើង សម្រាប់បំពេញបន្ថែមនូវចំណុចខ្វះខាតនានា។

- យុទ្ធសាស្ត្រដែលរដ្ឋាភិបាល កំពុងតែអនុវត្តន៍ទៅលើយុទ្ធសាស្ត្ររកប្រាក់ចំណូលរយៈពេលមធ្យមដ៏មានប្រសិទ្ធភាព រដ្ឋាភិបាលគួរតែដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត ដើម្បីធ្វើឱ្យអ្នកវិនិយោគលើវិស័យអចលនទ្រព្យមានការវិនិយោគបន្ថែមទៀតដូចជា ផ្លូវថ្នល់ ផ្លូវដែក ស្ពានអាកាសជាដើម ។
- ជំរុញឱ្យធនាគារផ្តល់ឥណទានអចលនទ្រព្យ នៅក្នុងលក្ខខណ្ឌមួយសមរម្យជាមួយនឹងអត្រាការប្រាក់សមស្របសម្រាប់ធ្វើការវិនិយោគរយៈពេលវែង និងបានបង្កើតមូលនិធិឯកទេសសម្រាប់ជួយទៅដល់ការគាំទ្រគម្រោងអភិវឌ្ឍអចលនទ្រព្យដែលមានសក្តានុពលខ្ពស់។

- គួរតែបង្កើតកម្មវិធីបណ្តុះបណ្តាលទាក់ទៅនឹងការវិនិយោគលើវិស័យអចលនទ្រព្យកាន់តែល្អ ព្រោះជាចំណែកមួយដែលអាចឱ្យអ្នកវិនិយោគយល់ដឹងច្បាស់ស៊ីជម្រៅជាងមុនជៀសវាងមានបញ្ហាក្រោយពេលវិនិយោគដែលជាចំណែកមួយក្នុងការជួយឱ្យវិស័យអចលនទ្រព្យកាន់តែដើរទៅមុខ។

# ឯកសារយោង


1. សឹក ចិន្តា, ស៊ន់ សារាយ, សុន ស្រីនាថ, មាស លីនដា, ជុំ សុភារី. (ឆ្នាំ២០២៣). *សារៈសំខាន់នៃការវិនិយោគលើវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាន់ទី២០. នៃវិទ្យាស្ថាន វ៉ាន់ដា. សន្លឹកទី៤ ទំព័រទី៣២
2. Wikipedia. (2024, January 10). *សេដ្ឋកិច្ច.* Retrieved March, 7 2025, from https://km.wikipedia.org/wiki/សេដ្ឋកិច្ច
3. Wikipedia. (2024, January 10). *ប្រព័ន្ធសេដ្ឋកិច្ច.* Retrieved March, 7 2025, from https://km.m.wikipedia.org/wiki/ប្រព័ន្ធសេដ្ឋកិច្ច
4. Wikipedia. (2024, December 14). *ប្រវត្តិកម្ពុជា.* Retrieved March, 7 2025, from https://km.m.wikipedia.org/wiki/ប្រវត្តិកម្ពុជា
5. Wikipedia. (2025, March 30). *គោលនយោបាយកម្ពុជា.* Retrieved March, 8 2025, from https://km.m.wikipedia.org/wiki/ *គោលនយោបាយកម្ពុជា*
6. នុតខុន វ៉ាយុត្តិ. (2024, September 7). *ចក្ខុវិស័យនៅកម្ពុជា.* Retrieved March, 10 2025, from https://www.undp.org/cambodia/
7. HARBORPROPERTY. (2022. June 30). *កត្តានៃការវិនិយោគលើវិស័យអចលនទ្រព្យមានការរីចម្រើន* Retrieved March, 10 2025, from https://www.harbor-property.com/km/wiki/detail/429/
8. KHsearch. វិប្បធម៌ទូទៅ. (2019, August 16). *តើវិស័យអចលនទ្រព្យបានចូលរួមដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាដូចម្ដេចខ្លះ?* Retrieved March, 10 2025, from https://www.khsearch.com/qna/23989.
9. PHKASLA PARTNER. Chamroeun. (2022. March 24). *អចលទ្រព្យជាអ្វី?* Retrieved March, 10 2025, from https://phkaslapartner.com/business-kamsan/what-is-properties/
10. KHsearch. ពន្ធ. (2020, January 23)*.តើពាក្យអចលនទ្រព្យសំដៅលើអ្វី?* Retrieved March, 10 2025, from https://www.khsearch.com/qna/28626
11. Investopedia. JAMESCHEN. (2020, May 31). *What Is Real Estate?* Retrieved March, 10 2025, from https://www.investopedia.com/terms/r/realestate.asp
12. Property. ម៉ាណេត. (2021, July 30). *តើអចលនទ្រព្យនៅប្រទេសកម្ពុជាមានប៉ុន្មានប្រភេទ?* Retrieved March, 12 2025, from https://propertyarea.asia/archives/78090
13. ហុក ហេង. (2019, December 12). *និយមន័យការវិនិយោគ.* Retrieved March, 12 2025, from https://www.khsearch.com/qna/27823
14. Paul Miller. (2016, February 9). *A Brief History of* Investments. Retrieved March, 15 2025, from https://www.paulmilleradvisor.com/blog/brief-history-investments
15. កាក់សេន-Kakcent. (2021, January 22). *ប្រភេទនៃការវិនិយោគ.* Retrieved March, 15 2025, from https://www.facebook.com/kakcentkh/posts/
16. អង្គភាពទិន្នន័យអំពីការអភិវឌ្ឍ. (2021, February 12). *ការវិនិយោគ.* Retrieved March, 20 2025, from https://opendevelopmentcambodia.net/km/topics/investment/
18. KHsearch. Chanheng Menh. (2021, April 5). *និយមន័យសេដ្ឋកិច្ច.* Retrieved March, 20 2025, from https://www.khsearch.com/profile/Chanheng_Menh

# ឧបសម្ព័ន្ធ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ១៩៣
ថ្ងៃ: ព្រ.ទី ២០ ខែតុលា ឆ្នាំ២០២១
ម៉ោង: ១៧:០០

## ព្រះរាជក្រម

នស/រកម/១០២១/០១៦

### យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ [illegible]ទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ [illegible]/២០២១ កបធ.ច ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ហើយដែលមានសេចក្តីទាំងស្រុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# ក្រសួងអប់រំ យុវជន និងកីឡា
# វិទ្យាស្ថាន វ៉ាន់ដា

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ
## ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

# ប្រធានបទ៖ សារៈសំខាន់នៃការវិនិយោគលើវិស័យ អចលនទ្រព្យនៅប្រទេសកម្ពុជា

**TOPIC: THE IMPORTANCE OF INVESTING IN REAL ESTATE IN CAMBODIA**

រៀបរៀងដោយនិស្សិត៖ ១-និស្សិត សឹក ចិន្តា B20/813
២-និស្សិត ស៊ន់ សារាយ B20/1025
៣-និស្សិត សុន ស្រីនាថ B20/482
៤-និស្សិត ហាស លីនដា B20/1637
៥-និស្សិត ជុំ សុគាទី B20/1979

៖ យ៉ាក ឫទ្ធី

016.258
មក្រុម សឹក ចិន្តា
VIA.PP/2023

## និស្សិតជំនាន់ទី២០

ាជធានីភ្នំពេញ - ឆ្នាំ២០២៣

PHNOM PENH-2023